ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

ក្រសួងសាធារណការ និងដឹកជញ្ជូន

Ministry of Public Works and Transport

# សៀវភៅណែនាំស្តីអំពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់

# ROAD ENVIRONMENTAL GUIDEBOOK



២០១៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ ៖ ៤៣៩ ប្រក ស.ក

ថ្ងៃព្រហ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៩

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំ ស្តីពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការ កែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញប្រកាសលេខ២២៧ សក.ប្រក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំឆ្នាំ២០១៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានផែនការ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ ១**.- ត្រូវបានដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់ បោះពុម្ពឆ្នាំ ២០១៩ ។

**ប្រការ ២**.- រាល់ការងារអនុវត្តគម្រោងលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ថ្នល់ និងស្ពាន ចាំបាច់ត្រូវអនុលោមតាមសៀវភៅណែនាំ ស្តីពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់ ដូចមានចែងនៅក្នុងប្រការ ១ ។

**ប្រការ ៣**.- រាល់ការកែប្រែ ឬ បន្ថែមទៅលើខ្លឹមសារបច្ចេកទេសទាំងឡាយ ដែលមានចែងនៅក្នុងសៀវភៅណែនាំ ដូចមានចែងនៅក្នុង ប្រការ ១ ត្រូវមានការណែនាំជាថ្មីរបស់ក្រសួង សាធារណការ និង ដឹកជញ្ជូន ។

**ប្រការ ៤**.- នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការនិងគោលនយោបាយ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន អង្គភាព ក្រោមឱវាទក្រសួង មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាន់ជំហរ និងឆន្ទៈយ៉ាងមោះមុតថា នឹងបន្តកិច្ចខិតខំប្រឹងប្រែងជំរុញការកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ជាគោលនយោបាយអាទិភាព។ ឆ្ពោះទៅរកគោលដៅចម្បងជាយុទ្ធសាស្ត្រខាងលើនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន បាននិងបន្តផ្តល់អាទិភាព ចំពោះការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ថែរក្សា និងបន្តពង្រីករាល់សមិទ្ធផល ដែលសម្រេចបានឱ្យបានគង់វង្សយូរអង្វែង។

ដើម្បីរួមចំណែកធានាបាននូវនិរន្តរភាពបរិស្ថាន ក្នុងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានកិច្ចសហការល្អជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) តាមរយៈគម្រោងពង្រឹងសមត្ថភាពលើការពិចារណាផ្នែកបរិស្ថាន និងសង្គមក្នុងអង្គភាពប្រតិបត្តិលើវិស័យផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា(CESCoR) បានរៀបចំចងក្រងឯកសារស្តីពី សៀវភៅណែនាំស្តីពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់(Road Environmental Guidebook) នេះឡើងក្នុងគោលបំណងដូចខាងក្រោម ៖

- ធ្វើឱ្យប្រសើរឡើងសមត្ថភាពខាងផ្នែកបច្ចេកទេសរបស់មន្ត្រីជំនាញក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបន្ទុកផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន(EMP) ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន។
- បញ្ជាក់ពីការងារពាក់ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន លើការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន(EMP) ក្នុងវិស័យផ្លូវថ្នល់ក្នុងនាមជាម្ចាស់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាននៅប្រទេសកម្ពុជា។

សៀវភៅណែនាំស្តីពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់ គឺមិនមែនជាគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)ក្នុងវិស័យផ្លូវថ្នល់នៅប្រទេសកម្ពុជានោះទេ។ សៀវភៅណែនាំនេះ នឹងរួមចំណែកបង្កើនសមត្ថភាព ក្នុងការអនុវត្តការងារបរិស្ថាននៅក្នុងគម្រោងអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន ឱ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពការងារខ្ពស់។

ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងសាធារណការ និងដឹកជញ្ជូន ខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងការកោតសរសើរដល់ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ក្នុងការគាំទ្រទាំងថវិកា និងបច្ចេកទេស ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីគម្រោងដែលបានខិតខំប្រឹងប្រែងរៀបចំសៀវភៅណែនាំនេះឱ្យបានចេញជារូបរាងឡើង។

ថ្ងៃព្រហ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

# មាតិកា

**និយមន័យពាក្យបច្ចេកទេស....................i**

**ជំពូកទី១ សេចក្តីផ្តើម....................1**

១.១ សាវតា....................1

១.២ គោលបំណង និងវិសាលភាពនៃសៀវភៅណែនាំ(REG)....................1

១.៣ ជំហានទូទៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន....................2

១.៣.១ ការធ្វើចំណាត់ថ្នាក់គម្រោង....................2

១.៣.២ ការកំណត់វិសាលភាពនៃគម្រោង....................3

១.៣.៣ ការប្រមូលទិន្នន័យគោលនៅក្នុងតំបន់គម្រោង....................3

១.៣.៤ ការវាយតម្លៃហេតុប៉ះពាល់....................3

១.៣.៥ ការគិតគូរពីវិធានការកាត់បន្ថយ....................3

១.៣.៦ ការគិតគូរពីផែនការគ្រប់គ្រងបរិស្ថាន....................3

១.៤ វដ្តគម្រោង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន....................3

១.៤.១ វដ្តគម្រោងទូទៅ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន....................3

១.៤.២ វដ្តគម្រោងផ្លូវថ្នល់ និងជំហាន វ.ហ.ប....................4

**ជំពូកទី២ ច្បាប់ អនុក្រឹត្យនិង ប្រកាសសំខាន់ៗដែលពាក់ព័ន្ធ....................6**

**ជំពូកទី៣ ដំណាក់កាលនៃដំណើរការ វ.ហ.ប និងការចូលរួមដោយក្រសួងសាធារណការ និងដឹកជញ្ជូននៅប្រទេសកម្ពុជា....................12**

៣.១ ដំណាក់កាលនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា....................12

៣.១.១ ដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ....................12

៣.១.២ ដំណាក់កាលពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប....................13

៣.១.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន....................14

៣.២ ការចូលរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនតាមដំណាក់កាលខ្លះនៃដំណើរការ វ.ហ.ប ក្នុងប្រទេសកម្ពុជា....................14

៣.២.១ ដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន....................14

៣.២.២ ដំណាក់កាលពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន....................15

៣.២.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន....................15

**ជំពូកទី៤ វិធីសាស្រ្តចូលរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងដំណើរការវ.ហ.ប នៅប្រទេសកម្ពុជា....................18**

៤.១ ដំណាក់កាលរៀបចំរបាយការណ៍ វ.ហ.ប....................18

៤.១.១ មាតិកានៃរបាយការណ៍ វ.ហ.ប....................18

៤.២ ដំណាក់កាលពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ....22
៤.២.១ សេចក្តីផ្តើមនៃការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ....22
៤.២.២ វិធីសាស្រ្តក្នុងការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ....22
៤.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន ....28
៤.៣.១ សេចក្តីផ្តើមនៃការអង្កេតតាមដានបរិស្ថាន....28
៤.៣.២ ចំណាត់ថ្នាក់នៃការអង្កេតតាមដានបរិស្ថាន ....28

**ឧបសម្ព័ន្ធ ....31**

ឧបសម្ព័ន្ធ ១ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យរបាយការណ៍ វ.ហ.ប លើគម្រោងផ្លូវថ្នល់....31
ឧបសម្ព័ន្ធ ២ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យផែនការគ្រប់គ្រងបរិស្ថានលើគម្រោងផ្លូវថ្នល់ ....36
ឧបសម្ព័ន្ធ ៣ បញ្ជីផ្ទៀផ្ទាត់សម្រាប់ពិនិត្យផែនការអង្កេតតាមដានបរិស្ថានលើគម្រោងផ្លូវថ្នល់....39
ឧបសម្ព័ន្ធ ៤ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យរបាយការណ៍អង្កេតតាមដានបរិស្ថានលើគម្រោងផ្លូវថ្នល់.41

# និយមន័យពាក្យបច្ចេកទេស

**ការវិភាគជម្រើស** (Alternatives Analysis)

គឺជាការវាយតម្លៃពីជម្រើសខុសៗគ្នាលើការសម្រេចគោលបំណងក្នុងការគ្រប់គ្រងគម្រោងណាមួយ។ វាជាការវិភាគបែបប្រៀបធៀបទៅលើកត្តាផ្សេងៗគ្នាដូចជា ថ្លៃប្រត្តិបត្តិការ ហានិយភ័យ ប្រសិទ្ធិភាព និង កង្វះខាតសមត្ថភាពក្នុងប្រត្តិបត្តិការ។

**ការវិភាគថ្លៃដើម និងផលចំណេញ** (Cost-Benefit Analysis)

គឺជាដំណើរការបែបប្រព័ន្ធក្នុងការគណនា និងការប្រៀបធៀបថ្លៃដើម និងផលចំណេញនៃការសម្រេចគោលនយោបាយ(គោលនយោបាយរដ្ឋាភិបាល) ឬក៏គម្រោង(ជាទូទៅ)។

**បណ្តុំហេតុប៉ះពាល់** (Accumulative Impacts)

ការប្រមូលផ្តុំនៃហេតុប៉ះពាល់ជាច្រើនដែលបណ្តាលមកពីគម្រោងមានស្រាប់ គម្រោងដែលបានស្នើ និងគម្រោងនាពេលអនាគត ដែលអាចបណ្តាលឲ្យមានហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន តែនឹងមិនអាចកើតមានឡើងក្នុងករណីគម្រោងមានតែមួយ។

**ដៃគូអភិវឌ្ឍន៍** (Development Partners)

ម្ចាស់ជំនួយបរទេស ដែលជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាថវិកា ឬបច្ចេកទេសដូចជា ធនាគារពិភពលោក(WB) ធនាគាអភិវឌ្ឍន៍អាស៊ី(ADB) ភ្នាក់ងារសហាប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ភ្នាក់ងារសហាប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) ជាដើម ។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** (Environmental Impact Assessment)

គឺជាការវាយតម្លៃលម្អិតទៅលើ ធនធាន និងបរិស្ថានរូបសាស្ត្រ ធនធានជីវសាស្ត្រ សេដ្ឋកិច្ចសង្គម ដោយផ្អែកជាចម្បងលើទិន្នន័យបឋមនៅក្នុង និងជុំវិញទីតាំងគម្រោង។ វាបង្កើតឲ្យមានមូលដ្ឋានសម្រាប់ ការកំណត់ ការព្យាករណ៍ និងការវិភាគហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលមានសក្តានុពលបណ្តាលមកពីសកម្មភាពគម្រោង។ម្យ៉ាងទៀតវាមានគោលបំណងកំណត់ពីវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន និងជម្រុញឲ្យមានហេតុប៉ះពាល់វិជ្ជមានជាអតិប្បរមា។

**ផែនការអង្កេតតាមដានបរិស្ថាន** (Environmental Monitoring Plan)

គឺជាផែនការលម្អិតរបស់គម្រោង ក្នុងការផ្ទៀងផ្ទាត់ពីប្រសិទ្ធិភាពនៃការអនុវត្តវិធានការកាត់បន្ថយក្នុងអំឡុងពេលសាងសង់ និង ប្រតិបត្តិគម្រោង។

**របាយការណ៍ត្រួតពិនិត្យបរិស្ថាន** (Environmental Monitoring Report)

គឺជារបាយការណ៍ដែលមានពេលកំណត់ រួមបញ្ចូលទាំងទិន្នន័យត្រួតពិនិត្យ ដោយផ្ទៀងផ្ទាត់ទៅនឹងកម្រិតអភិរក្ស ដើម្បីបញ្ជាក់ពីប្រសិទ្ធិភាពនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ក្នុងអំឡុងពេលសាងសង់ និងប្រតិបត្តិគម្រោង។

**ផែនការគ្រប់គ្រងបរិស្ថាន (Environmental Management Plan)**

ផែនការគម្រោងលម្អិតបង្កើតឡើង ដើម្បីអនុវត្តការគ្រប់គ្រង បរិស្ថានឲ្យបានសមស្របក្នុងអំឡុងពេលសាងសង់ និងឬប្រតិបត្តិគម្រោង។

**ការវាយតម្លៃបរិស្ថាន (Environmental Assessment)**

ពាក្យទូទៅដែលប្រើសម្រាប់ពិពណ៌នាពីដំណើរការនៃការវិភាគ និង ការធ្វើផែនការបរិស្ថាន ក្នុងការដោះស្រាយហេតុប៉ះពាល់បរិស្ថាន និងហានិយភ័យនានាដែលទាក់ទងនឹងគម្រោង។ ការវាយតម្លៃនេះអាចមានទម្រង់ជា EIA IEE ឬ Matrix ។

**ការអង្កេតបរិស្ថាន (Environmental Investigation)**

ជាផ្នែកនៃការស្ទង់មតិមួយនៃការសិក្សាEIA។ សកម្មភាពចម្បងនៃការអង្កេត គឺការចុះពិនិត្យទីតាំងគម្រោង និងការប្រមូលទិន្នន័យគោលក្នុងបរិបទបរិស្ថាននាពេលបច្ចុប្បន្ន។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA ឬ IEE)**

ជាការវាយតម្លៃបឋមលើធនធាន និងបរិស្ថាន រូបសាស្ត្រ ជីវសាស្ត្រ សេដ្ឋកិច្ចសង្គមនៅក្នុងទីតាំងគម្រោង និងតំបន់ជុំវិញទីតាំងគម្រោង។ ការសិក្សាវាយតម្លៃផ្តោតលើជាមូលដ្ឋានក្នុងការកំណត់ព្យាករណ៍ និងការវិភាគហេតុប៉ះពាល់ដែលមានសក្តានុពលលើបរិស្ថាន និងសង្គម ព្រមទាំងការកំណត់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងជំរុញហេតុប៉ះពាល់វិជ្ជមានជាអតិប្បបរមា។

**វិធានការកាត់បន្ថយហេតុប៉ះពាល់ (Mitigation Measures)**

វិធានការនេះមានទម្រង់ជាបែបផែន និងមិនបែបផែន ក្នុងការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើបរិស្ថាន និងសេដ្ឋកិច្ចសង្គម។

**ម្ចាស់គម្រោង (Project owner)**

គឺអ្នកអភិវឌ្ឍគម្រោង ឬដែលមានកម្មសិទ្ធលើគម្រោង ទាំងជាបុគ្គល ឬអង្គភាពដែលទទួលបានការយល់ព្រមលើការសិក្សា ការរុករក ការរចនា ការសាងសង់ និងការអនុវត្តគម្រោង។ ម្ចាស់គម្រោងអាចជាស្ថាប័នរដ្ឋាភិបាល ឬឯកជន ដែលទទួលខុសត្រូវលើគម្រោងអភិវឌ្ឍន៍នោះ។

**ការចូលរួមជាសាធារណៈ (Public Participation)**

គឺជាការចូលរួមពីភាគីទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍រួមមាន ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា អ្នកតំណាងជនរងផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាល។

**ការកំណត់វិសាលភាពគម្រោង (Scoping)**

សំដៅលើការជ្រើសរើសជំរើសសម្រាប់ការវិភាគហេតុប៉ះពាល់ បរិស្ថានចម្បងៗ និងវិធីសិក្សា។

**ការធ្វើចំណាត់ថ្នាក់គម្រោង (Screening)**

សំដៅលើការធ្វើចំណាត់ថ្នាក់គម្រោងដែលស្នើឡើង ថាតើកម្រិតហេតុប៉ះពាល់គម្រោងតម្រូវឲ្យធ្វើការ

សិក្សាEIA ឬមិនសិក្សាEIA? ដៃគូអភិវឌ្ឍន៍ជាទូទៅធ្វើចំណាត់ថ្នាក់គម្រោងដែលស្នើឡើងជា៤ក្រុម A B C និងFI។

**អ្នកពាក់ព័ន្ធ (Stakeholder)**

គឺជាមនុស្សដែលមានចំណាប់អារម្មណ៍ មនុស្សដែលទទួលរងប៉ះពាល់ពីគម្រោងវិនិយោគ។

**លក្ខខណ្ឌការងារ (Term of Reference)**

គឺជាតម្រូវការ តាមបែបបទបច្ចេកទេស នីតិវិធី និងរដ្ឋបាល។ លក្ខខណ្ឌការងារនៃការសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសំដៅលើធាតុ វិសាលភាព និងវិធីសាស្ត្រវិភាគជាក់លាក់ សម្រាប់ការរៀបរាប់ពីគម្រោង តំបន់គម្រោង ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ ការវិភាគជម្រើស ការចូលរួមជាសាធារណៈ ការកំណត់ពីហេតុប៉ះពាល់ដែលអាចកើតមានឡើងទៅលើសេដ្ឋកិច្ចសង្គម និងបរិស្ថាន វិធានការកាត់បន្ថយខ្លឹមសារ និងគ្រោងឆ្អឹងនៃរបាយការណ៍។

# ជំពូកទី១ សេចក្តីផ្តើម

## ១.១ សាវតា

នៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការបង្កើតលេខាដ្ឋានគ្រប់គ្រងបរិស្ថាន ដែលជាអង្គភាពដឹកនាំ និងមានភារកិច្ចគ្រប់គ្រង និងអភិរក្សបរិស្ថាន និងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ ក្រោយមកលេខាធិការដ្ឋាននេះ បានប្តូរទៅជាក្រសួងបរិស្ថាននៅក្នុងឆ្នាំ១៩៩៦។ នៅឆ្នាំ១៩៩៧ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបង្កើតឡើង ។

ដើម្បីធានាការអភិវឌ្ឍប្រកបដោយនិរន្តភាពនៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានតម្រូវឱ្យគម្រោងអភិវឌ្ឍស្នើសុំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(វ.ហ.ប) មុនពេលធ្វើសេចក្តីសម្រេចថាតើគម្រោងអភិវឌ្ឍនោះគួរត្រូវបានអនុញ្ញាតិឱ្យដំណើរការ ឬមិនឱ្យដំណើរការ។ យោងតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(១៩៩៦) និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(១៩៩៩) ក្រសួងបរិស្ថានមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ(វ.ហ.ប.ដ/វ.ហ.ប) ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(វ.ហ.ប) សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នានា តម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរបាយការណ៍នេះត្រូវពិនិត្យ និងផ្តល់យោបល់ដោយក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធដទៃទៀត មុនពេលស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា។

ក្រុមការងារ វ.ហ.ប ត្រូវបានបង្កើតឡើង ដើម្បីរៀបចំសៀវភៅណែនាំស្តីពីបរិស្ថានសម្រាប់វិស័យផ្លូវថ្នល់។ សៀវភៅណែនាំនេះ គឺសម្រាប់ជួយសម្រួលដល់មន្ត្រីជំនាញទទួលបន្ទុកខាង វ.ហ.ប របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប និងអនុវត្តផែនការគ្រប់គ្រងបរិស្ថានឱ្យកាន់តែមានប្រសិទ្ធភាព។ សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងក្រោមជំនួយបច្ចេកទេស ពីអ្នកជំនាញការJICA និងណែនាំដោយមន្ត្រីជំនាញពីនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។

## ១.២ គោលបំណង និងវិសាលភាពនៃសៀវភៅណែនាំ(REG)

គោលបំណងនៃសៀវភៅណែនាំនេះ គឺជួយដល់មន្ត្រីជំនាញទទួលបន្ទុកការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ វ.ហ.ប និង ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានសម្រាប់វិស័យផ្លូវថ្នល់ ដើម្បីធានាឱ្យមានការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តភាពក្នុងវិស័យផ្លូវថ្នល់ ។

សៀវភៅណែនាំនេះ នឹងត្រូវបានប្រើប្រាស់ដោយមន្ត្រីជំនាញនៃក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ក្រសួង ដើម្បីបំពេញការងារ ឬភារកិច្ចដែលទាក់ទងនឹង

ការងារ វ.ហ.ប។ ដូច្នេះហើយសៀវភៅណែនាំនេះត្រូវតែ ជាក់លាក់ និងអាចអនុវត្តបាន ដោយផ្អែកលើជំនាញបច្ចេកទេស និងចំណេះដឹងនៃការសិក្សា។

សៀវភៅណែនាំនេះ គឺមិនមែនជាគោលការណ៍ណែនាំវ.ហ.បសម្រាប់វិស័យផ្លូវថ្នល់នៅប្រទេសកម្ពុជានោះទេ។ ក្រសួងបរិស្ថាន នឹងរៀបចំគោលការណ៍ណែនាំស្តីពី វ.ហ.ប សម្រាប់វិស័យផ្លូវថ្នល់ក្នុងប្រទេសកម្ពុជានាពេលអនាគត។

វិសាលភាពនៃសៀវភៅណែនាំ គឺមានដូចខាងក្រោម៖

- ជំនួយស្មារតីដល់មន្ត្រីជំនាញនៃក្រសួងសាធារណការ និងដឹកជញ្ជូន ដែលទទួលបន្ទុកទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) ផែនការគ្រប់គ្រងបរិស្ថាន(EMP) ផែនការអង្កេតតាមដានបរិស្ថាន(EMoP) របាយការណ៍អង្កេតតាមដានបរិស្ថាន(EMoR) ដើម្បីយល់ដឹងពីចំណុចសំខាន់ៗ និងការប្រើប្រាស់ការយល់ដឹងនេះ ធ្វើឱ្យគុណភាពរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ផែនការគ្រប់គ្រងបរិស្ថាន ផែនការអង្កេតតាមដានបរិស្ថាន របាយការណ៍អង្កេតតាមដានបរិស្ថានមានភាពប្រសើរឡើង។
- ឧបសម្ព័ន្ធត្រូវបានរៀបរៀងឡើងប្រកបដោយភាពជាក់លាក់ ដើម្បីជំរុញប្រសិទ្ធភាពនៃការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ផែនការគ្រប់គ្រងបរិស្ថាន(EMP) ផែនការអង្កេតតាមដានបរិស្ថាន(EMoP) និងរបាយការណ៍អង្កេតតាមដានបរិស្ថាន(EMoR) នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។
- សៀវភៅណែនាំនេះផ្តោតលើទិដ្ឋភាពផ្នែកសង្គម និងបរិស្ថាន ប៉ុន្តែមិនបានផ្តោតទៅលើការដោះស្រាយផលប៉ះពាល់នៃគម្រោង(Resettlement Issues) នោះឡើយ។ ប្រទេសកម្ពុជាមាននីតិវិធីក្នុងការដោះស្រាយផលប៉ះពាល់នៃគម្រោង (Basic Resettlement Procedures) ដែលត្រូវបានរៀបចំឡើងរួមគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រោមរូបភាពគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ពីគម្រោង (Inter-ministerial Resettlement Committee)។
- សៀវភៅណែនាំនេះផ្តោតលើគម្រោងផ្លូវថ្នល់ និងស្ពានតែប៉ុណ្ណោះ។

## ១.៣ ជំហានទូទៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ជាទូទៅ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានជំហានសំខាន់ៗចំនួន៦ ដូចខាងក្រោម៖

### ១.៣.១ ការធ្វើចំណាត់ថ្នាក់គម្រោង

គោលបំណងនៃការធ្វើចំណាត់ថ្នាក់គម្រោង គឺការកំណត់ថាតើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញតម្រូវឱ្យអនុវត្ត ឬមិនអនុវត្ត។ នីតិវិធីនៃការធ្វើចំណាត់ថ្នាក់គម្រោង គឺប្រើសម្រាប់ធ្វើចំណាត់ថ្នាក់បញ្ហាបរិស្ថាន ដែលកើតឡើងពីគម្រោង។ ប្រព័ន្ធធ្វើចំណាត់ថ្នាក់គម្រោងដែលត្រឹមត្រូវអាចបញ្ជាក់ថាជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការជៀសវាងការប្រើប្រាស់ពេលវេលាមិនចាំបាច់ក្នុងការវាយតម្លៃគម្រោងដែលមានបញ្ហាបរិស្ថានតិចតួច ។

### ១.៣.២ ការកំណត់វិសាលភាពនៃគម្រោង

គោលបំណងនៃដំណើរការកំណត់វិសាលភាពនេះ គឺដើម្បីកំណត់បញ្ហាបរិស្ថាន និងសង្គម ក៏ដូចជាការកំណត់ពីព្រំដែននៃការសិក្សា និងកំណត់លក្ខខណ្ឌការងារ(Term of Reference)នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជារួម ការកំណត់វិសាលភាពនៃគម្រោងគឺ ដើម្បីកំណត់បញ្ហាគន្លឹះសំខាន់ៗចំនួន០៣ (១)ជម្រើសទីតាំង(Site alternatives) (២)ជម្រើសរចនាបទ (Design alternatives) និង (៣)ភាពសមហេតុផលរបស់គម្រោង (Justification for the project)។

### ១.៣.៣ ការប្រមូលទិន្នន័យគោលនៅក្នុងតំបន់គម្រោង

ការប្រមូលទិន្នន័យគោលផ្នែករូបសាស្ត្រ ជីវសាស្ត្រ សេដ្ឋកិច្ចសង្គម និងវប្បធម៌នៅក្នុងទីតាំងគម្រោង គឺជាឯកសារយោងដ៏សំខាន់សម្រាប់ការរៀបចំសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការពិពណ៌នាពីបរិស្ថាន សេដ្ឋកិច្ចសង្គម និងវប្បធម៌ ដោយរួមបញ្ចូលទាំងលក្ខណៈនៃទីតាំងដែលនឹងមានសកម្មភាពគម្រោងកើតមានឡើង។

### ១.៣.៤ ការវាយតម្លៃហេតុប៉ះពាល់

លក្ខណៈនៃហេតុប៉ះពាល់ដែលមានសក្តានុពលគឺត្រូវបានកំណត់ វាយតម្លៃ និងព្យាករណ៍ ដោយផ្អែកលើទិន្នន័យគោល និងសកម្មភាពនៃគម្រោង(ទំនាក់ទំនងហេតុ និងផល)។ ការព្យាករណ៍ហេតុប៉ះពាល់ជាធម្មតាត្រូវបានអនុវត្តដោយការប្រើប្រាស់វិធីសាស្ត្រ ម៉ូឌែល(Models)សាមញ្ញ និងតាមបទពិសោធន៍អ្នកជំនាញការជាដើម។

### ១.៣.៥ ការគិតគូរពីវិធានការកាត់បន្ថយ

ក្រោយពេលហេតុប៉ះពាល់សំខាន់ៗត្រូវបានវិភាគ ឥទ្ធិពលនៃហេតុប៉ះពាល់ទាំងនោះនឹងត្រូវបានកំណត់ ។ វិធានការការពារ ការកែលម្អ និងការទូទាត់សំណង សម្រាប់ហេតុប៉ះពាល់នីមួយៗត្រូវបានកំណត់ និងពិចារណា។ វិធានការកាត់បន្ថយហេតុប៉ះពាល់ជាធម្មតារួមមានផ្នែកបច្ចេកទេស សង្គម និងស្ថាប័ន ត្រូវបានបញ្ចូលជាធាតុផ្សំរួមសម្រាប់គម្រោង។

### ១.៣.៦ ការគិតគូរពីផែនការគ្រប់គ្រងបរិស្ថាន

ជាទូទៅ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានរៀបចំជាផ្នែកមួយនៃដំណើរការ វ.ហ.ប។ ផែនការគ្រប់គ្រងបរិស្ថាន គឺជាការប្រែពីវិធានការកាត់បន្ថយហេតុប៉ះពាល់ និងវិធានការអង្កេតតាមដានទៅជាសកម្មភាពអនុវត្តជាក់ស្តែង ហើយត្រូវអនុវត្តដោយម្ចាស់គម្រោង។ ផែនការគ្រប់គ្រងបរិស្ថានអាចត្រូវបានរួមបញ្ចូលទៅក្នុងរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ឬក៏ក្នុងរបាយការណ៍មួយផ្សេងដាច់ដោយឡែក ដោយអាស្រ័យលើលក្ខន្តិកៈជាក់ស្តែង។

## ១.៤ វដ្តគម្រោង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ១.៤.១ វដ្តគម្រោងទូទៅ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ជាទូទៅ គម្រោងអភិវឌ្ឍន៍ អាចសម្រេចជោគជ័យបានដោយជំហានចំនួន៦ មានដូចជា៖ (១)ទស្សនទានស្តីពីគម្រោង (២)បុរេសមិទ្ធិលទ្ធភាព (៣)សមិទ្ធិលទ្ធភាព (៤)ការរចនានិងវិស្វកម្ម (៥)ការ

អនុវត្ត និង(៦)ការវាយតម្លៃ និងអង្កេតតាមដាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើរតួនាទីសំខាន់នៅក្នុងដំណាក់កាលនីមួយៗនៃវដ្តគម្រោង (យោងតាមរូបភាព១.១)។

ជាទូទៅ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចធ្វើបានក្នុងដំណាក់កាលបុរេសមិទ្ធិលទ្ធភាព និង សមិទ្ធិលទ្ធភាពនៃវដ្តគម្រោង ឬក៏ក្នុងដំណាក់កាលរៀបចំទស្សនទានស្តីពីគម្រោង។ រវាងដំណាក់កាលរៀបចំទស្សនទានស្តីពីគម្រោង និងបុរេសមិទ្ធិលទ្ធភាព ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រាប់បញ្ចូលការជ្រើសរើសទីតាំង ការធ្វើចំណាត់ថ្នាក់គម្រោង និងការកំណត់វិសាលភាពគម្រោង។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលម្អិត គឺចាប់ផ្តើមធ្វើឡើងនៅក្នុងដំណាក់កាលសមិទ្ធិលទ្ធភាព។

បន្ទាប់ពីព្យាករណ៍ពីហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចកំណត់ពីជម្រើសដំណោះស្រាយនានា ឬក៏គិតគូរពីដំណោះស្រាយដែលអាចបញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់ ដើម្បីធ្វើឱ្យប្រសើរឡើងការអនុវត្តផ្នែកបរិស្ថាននៃគម្រោង។

ផែនការគ្រប់គ្រងបរិស្ថាន (EMP) អាចត្រូវបានបញ្ជ្រាបចូលទៅក្នុងការរចនាគម្រោងវិស្វកម្ម និង ដំណាក់កាលប្រតិបត្តិនៃវដ្តគម្រោង។ ផែនការគ្រប់គ្រងបរិស្ថាន ដែលរៀបរាប់ពីវិធានការកាត់បន្ថយហេតុប៉ះពាល់ គឺត្រូវបានគិតគូរនៅក្នុងវដ្តគម្រោងចាប់ពីដំណាក់កាលប្រតិបត្តិគម្រោង (អំឡុងពេលសាងសង់ ប្រតិបត្តិការ និងការថែទាំ)។ គោលបំណងចម្បងនៃផែនការគ្រប់គ្រងបរិស្ថាន គឺដើម្បីកាត់បន្ថយហេតុប៉ះពាល់ដែលបណ្តាលមកពីគម្រោងផ្លូវថ្នល់។




**រូបភាព១.១ វដ្តគម្រោងទូទៅ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

## ១.៤.២ វដ្តគម្រោងផ្លូវថ្នល់ និងជំហាន វ.ហ.ប

គម្រោងផ្លូវថ្នល់ពាក់ព័ន្ធនឹងការសិក្សាបច្ចេកទេសមួយចំនួន ដែលមានសារៈសំខាន់សម្រាប់ដំណាក់កាលធ្វើផែនការ រចនាគម្រោង សាងសង់គម្រោង និងប្រតិបត្តិគម្រោង។ ដំណាក់កាលនានានៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តស្របតាមសកម្មភាពវដ្តនៃគម្រោង។

ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់វិស័យផ្លូវថ្នល់រួមមាន៖ ការសង្ខេបអំពីគម្រោង ការធ្វើចំណាត់ថ្នាក់គម្រោង ការកំណត់វិសាលភាពគម្រោង ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការពិនិត្យរបាយការណ៍ វ.ហ.ប និងការអនុម័ត ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ និងការអង្កេតតាមដានបរិស្ថាន។

វដ្តគម្រោងសម្រាប់គម្រោងផ្លូវថ្នល់ និង ដំណាក់កាល វ.ហ.ប នៅក្នុងដំណាក់កាលនីមួយៗនៃវដ្តគម្រោងមានបង្ហាញនៅក្នុងរូបភាព១.២ ។




**រូបភាព១.២ វដ្តគម្រោងផ្លូវថ្នល់ និងដំណាក់កាល វ.ហ.ប**

# ជំពូកទី២ ច្បាប់ អនុក្រឹត្យនិង ប្រកាសសំខាន់ៗដែលពាក់ព័ន្ធ

ខ្លឹមសារសំខាន់ៗនៃមាត្រាក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសទាក់ទងនឹងសៀវភៅណែនាំស្ដីអំពីបរិស្ថានក្នុងវិស័យផ្លូវថ្នល់ ត្រូវបានរៀបដូចខាងក្រោមៈ

## ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

មាត្រា៦

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន សាធារណៈ ហើយត្រូវពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមដំណើររបស់ក្រសួងបរិស្ថាន។

ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា ៧

ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និង រាល់គម្រោងដែលរដ្ឋស្នើរឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្ដល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គភាពមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៦

ក្រសួងបរិស្ថាន ត្រូវផ្ដល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

មាត្រា១៧

បែបបទនៃការចូលរួមរបស់សាធារណជន និងការស្រង់យកព័ត៌មានក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា ១៨

ព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមករវាងក្រសួងបរិស្ថាន និងក្រសួងនានា។

**អនុក្រឹត្យលេខ១៣៥អនក្រ បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ឆ្នាំ២០១៦**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដាន ការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានាដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន។
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។
- ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចសន្យាការពារបរិស្ថាន ដោយសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។[1]

**អនុក្រឹត្យលេខ៧២អនក្រ បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩**

មាត្រា ១

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពរបស់ឯកជនសាធារណៈ ហើយត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។
- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់ មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

មាត្រា ៣

ក្រសួងបរិស្ថានមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។
- តាមដាន ឃ្លាំមើលនិងចាត់វិធានការ ឱ្យម្ចាស់គម្រោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោងដូចមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។

[1] តួនាទី និងភារកិច្ចផ្សេងទៀតរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានរៀបរាប់នៅក្នុងអនុក្រឹត្យរបស់ក្រសួងបរិស្ថានលេខ ១៣៥

មាត្រា ៥

ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគម្រោងមានភារកិច្ចពិនិត្យ និងសម្រេចលើគម្រោងដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

មាត្រា ៦

ម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគម្រោងដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៧

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍សិក្សាបុរេសមិទ្ធិលទ្ធភាពទៅក្រសួងបរិស្ថាន។

មាត្រា ៨

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស៊ីស្ទែម សុខភាព និងសុខមាលភាពសាធារណៈ។

មាត្រា ១៤

ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ដូចមានចែងក្នុងមាត្រា៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចម្លងទៅស្ថាប័នអនុម័តគម្រោង។

មាត្រា ១៦

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឱ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ដូចមានចែងក្នុងមាត្រា៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគម្រោង។

មាត្រា ២៣

ម្ចាស់កម្មសិទ្ធិ ម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយពេល៦ខែគិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថានបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ។

**ប្រកាសលេខ៣៧៦របស់ក្រសួងបរិស្ថាន ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩**

ប្រការ ១

ប្រកាសនេះមានគោលបំណងអនុវត្តគោលការណ៍ណែនាំទូទៅស្តីពី ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

ប្រការ ៤

ម្ចាស់គម្រោងដូចមានចែងនៅក្នុង ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូង ឬពេញលេញដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។

ប្រការ ៥

ករណីម្ចាស់គម្រោង អាចសរសេររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូង ឬពេញលេញដោយខ្លួនឯងផ្ទាល់ នោះក្រុមសរសេររបាយការណ៍ត្រូវតែមានសមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍ ដោយមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

ប្រការ ៧

នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគម្រោង ដូចមានចែងនៅក្នុងប្រការ ២ និង៣ខាងលើ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ថា គម្រោងនេះគួរតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

ប្រការ ៩

នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានដំបូង ឬពេញលេញដោយអនុវត្តទៅតាមគោលការណ៍ណែនាំទូទៅនេះ។

ប្រការ១១

ក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានដំបូង ឬពេញលេញរបស់ក្រសួងបរិស្ថានដោយគិតចាប់ពីថ្ងៃទទួលរបាយការណ៍ជាផ្លូវការមានដូចខាងក្រោម៖

- មន្ត្រីជំនាញរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចុះពិនិត្យទីតាំងជាក់ស្តែង និងផ្តល់យោបល់ក្នុងរយៈពេល១០ថ្ងៃ
- អន្តរនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងបរិស្ថានមានរយៈពេល០៥ថ្ងៃ
- ថ្នាក់ដឹកនាំរបស់ក្រសួងបរិស្ថានមានរយៈពេល០៥ថ្ងៃ
- អន្តរក្រសួងមានរយៈពេល០៥ថ្ងៃដែលមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានានឹងគម្រោងវិនិយោគដោយមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។

ប្រការ១៣

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តមានរយៈពេល០៥ថ្ងៃ ដើម្បីធ្វើលិខិតជាផ្លូវការតាម

ប្រការ១១ និង១២ខាងលើ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ តំរូវឱ្យម្ចាស់គម្រោងធ្វើការកែសម្រួលលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញឡើងវិញ។

ក្នុងករណី ក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តផ្តល់យោបល់ទៅម្ចាស់គម្រោង ដើម្បីឱ្យកែសម្រួល នោះក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តពិនិត្យ និងផ្តល់យោបល់ឡើងវិញក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីទទួលបានរបាយការណ៍កែសម្រួលខាងលើពីម្ចាស់គម្រោង។

ប្រការ១៤

នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្ត មានភារកិច្ចតាមដាន ឃ្លាំមើល និងចាត់វិធានការឱ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាននៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្តបាន ឯកភាព។

**អនុក្រឹត្យលេខ ២១៦អនក្រ បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០១៦**

ប្រការ១៧

នាយកដ្ឋានផែនការ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន
- រៀបចំស្ថិតិ និងសម្របសម្រួលផែនការអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើបច្ចុប្បន្នកម្មផែនការ នូវរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងកិច្ចការសាធារណការ និងដឹកជញ្ជូននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសាធារណៈនិងឯកជននៅក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួល និងកៀរគរធនធានហិរញ្ញប្បទានសម្រាប់អភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន
- តាមដាន និងជម្រុញការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍រយៈពេលវែង មធ្យម និងខ្លី យុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ជាតិ ផែនការ៥ឆ្នាំ ផែនការ៣ឆ្នាំរំកិលកម្មវិធីវិនិយោគសាធារណៈ និងឯកជន ផែនការឆ្នាំលើការងារជួសជុលថែទាំផ្លូវថ្នល់ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនពហុរូបភាព និងផែនការភស្តុភារកម្ម
- ចូលរួមសហការលើការរៀបចំយុទ្ធសាស្ត្រ ការសិក្សាផែនការមេ និងផែនការអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន ភស្តុភារកម្ម ឬការរៀបចំយុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍន៍តាមអនុវិស័យ ផ្លូវថ្នល់ ការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក ផ្លូវសមុទ្រ កំពង់ផែ និងភស្តុភារកម្ម
- ចូលរួមសហការ និងពិនិត្យផ្តល់យោបល់លើការរៀបចំផែនការថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការងារសាធារណការ និងដឹកជញ្ជូន

- ពិនិត្យផ្តល់យោបល់ និងចូលរួមក្នុងសកម្មភាពវាយតម្លៃ និងដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច សង្គម ដោយសារគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណការ និងដឹកជញ្ជូន
- សិក្សាស្រាវជ្រាវ និងតាមដានការប្រែប្រួលនិន្នាការក្នុងតំបន់ និងពិភពលោក ដើម្បីកសាងគោលនយោបាយវិស័យសាធារណការ និងដឹកជញ្ជូន
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមការកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រកាសលេខ២២៧នៃក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានផែនការ ឆ្នាំ២០១៦**

ប្រការ ៧

ការិយាល័យបរិស្ថាន និងសង្គមមានភារកិច្ចដូចខាងក្រោមៈ

- ប្រមូលផ្តុំ រៀបចំចងក្រង ឯកសារនានាដែលពាក់ព័ន្ធទៅនឹងការងារបរិស្ថាន និងសង្គម
- ចូលរួមសហការរៀបចំឯកសារ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គម្រោងអភិវឌ្ឍន៍នានាក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- ផ្សព្វផ្សាយ បណ្តុះបណ្តាល អនុវត្តការងារបន្សាំ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- ចូលរួមសិក្សា រៀបចំគោលនយោបាយផលប៉ះពាល់ដែលរងប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- ចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ សិក្សា វាយតម្លៃអំពីផលប៉ះពាល់ និងរៀបចំរបាយការណ៍ស្តីពីការអង្កេតវាស់វែងលម្អិត (DMS) និងលទ្ធផលនៃការងារដោះស្រាយផលប៉ះពាល់ដែលរងប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- ត្រួតពិនិត្យ តាមដាន និងធ្វើរបាយការណ៍ពីការអនុវត្តទៅតាមក្របខណ្ឌនៃការគ្រប់គ្រងបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថានលើរាល់គម្រោងសាងសង់ ស្តារ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីធានាថាការអនុវត្តគម្រោងទាំងនោះ ស្របតាមគោលការណ៍គ្រប់គ្រងបរិស្ថានដែលបានកំណត់
- ចូលរួមរៀបចំ និងសហការការងារសង្គមកិច្ច និងគ្រោះមហន្តរាយពាក់ព័ន្ធក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
- រាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំនាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

# ជំពូកទី៣ ដំណាក់កាលនៃដំណើរការ វ.ហ.ប និងការចូលរួមដោយក្រសួងសាធារណការ និងដឹកជញ្ជូននៅប្រទេសកម្ពុជា

## ៣.១ ដំណាក់កាលនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា

### ៣.១.១ ដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

យោងតាមអនុក្រឹត្យលេខ៧២របស់ក្រសួងបរិស្ថានចុះនៅឆ្នាំ ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចែងថាម្ចាស់គម្រោងអាចរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយខ្លួនឯង ប្រសិនបើក្រុមជំនាញមានការទទួលស្គាល់ពីក្រសួងបរិស្ថាន ឬជួល ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យដែលទទួលស្គាល់ពីក្រសួងបរិស្ថានក៏បាន ។

ម្ចាស់គម្រោងត្រូវមានជំនាញបច្ចេកទេស និងគ្រប់គ្រង ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលក្រុមជំនាញត្រូវទទួលស្គាល់ដោយក្រសួងបរិស្ថាន ឬក្រុមហ៊ុនទីប្រឹក្សាឯករាជ្យអាចត្រូវបានជួលជាជំនួយដល់ម្ចាស់គម្រោងក៏បាន។ ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យត្រូវមានជំនាញបច្ចេកទេសគ្រប់គ្រាន់ក្នុងការសិក្សា និងការរៀបចំរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប និងត្រូវទទួលស្គាល់ដោយក្រសួងបរិស្ថាន។

យោងតាមប្រកាសលេខ៣៧៦របស់ក្រសួងបរិស្ថានស្តីពី គោលការណ៍ណែនាំទូទៅក្នុងរបាយការណ៍ហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ មាតិកានៃរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប មានទំរង់ដូចខាងក្រោម៖

| របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) | របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) |
|---|---|
| ខ្លឹមសារសង្ខេប | ខ្លឹមសារសង្ខេប |
| ជំពូក១ សេចក្តីផ្តើម | ជំពូក១ សេចក្តីផ្តើម |
| ជំពូក២ ក្របខ័ណ្ឌច្បាប់ | ជំពូក២ វិធីសាស្ត្រវាយតម្លៃ |
| ជំពូក៣ ការពិពណ៌នាអំពីគម្រោង | ជំពូក៣ ក្របខ័ណ្ឌច្បាប់ |
| ជំពូក៤ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់ | ជំពូក៤ ការពិពណ៌នាអំពីគម្រោង |
| ជំពូក៥ ការចូលរួមពីសាធារណជន | ជំពូក៥ ការពិពណ៌នាពីបរិស្ថានដែលមានស្រាប់ |
| ជំពូក៦ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ | ជំពូក៦ ការចូលរួមពីសាធារណជន |
| ជំពូក៧ ផែនការគ្រប់គ្រងបរិស្ថាន (EMP) | ជំពូក៧ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ |
| ជំពូក៨ សន្និដ្ឋាន និងអនុសាសន៍ | ជំពូក៨ ផែនការគ្រប់គ្រងបរិស្ថាន (EMP) |
| ឯកសារយោង | ជំពូក៩ ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន |
| ឧបសម្ព័ន្ធ | ជំពូក១០ សន្និដ្ឋាន និងអនុសាសន៍ |
| | ឯកសារយោង |
| | ឧបសម្ព័ន្ធ |

យោងតាមមាត្រា១៦នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ ១៩៩៦បញ្ជាក់ថា ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

ម្យ៉ាងទៀត គោលបំណងមួយនៅក្នុងអនុក្រឹត្យលេខ៧២របស់ក្រសួងបរិស្ថាន ចុះនៅឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានចែងថា បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង។

### ៣.១.២ ដំណាក់កាលពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប




អក្សរកាត់
**វ.ហ.ប.ដ** វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង **វ.ហ.ប** ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ **ក.អ.ក** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **ផគប** ផែនការអភិវឌ្ឍបរិស្ថាន **ក្រ.ប** ក្រសួងបរិស្ថាន **អ.គ.វ.រ.ខ** អនុគណកម្មការវិនិយោគរាជធានី ខេត្ត **ម.ប.រ.ខ** មន្ទីរបរិស្ថានរាជធានី ខេត្ត **ព.ប.ប** ពាក្យសុំពិនិត្យបញ្ហាបរិស្ថាន **ម.គ** ម្ចាស់គម្រោង

**រូបភាព៣.១ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងស្នើសុំដែលអនុម័តដោយស្ថាប័ន អនុម័តគម្រោង ក.អ.ក/អ.គ.វ.រ.ខ (ប្រភព យោងតាមប្រកាសក្រសួងបរិស្ថានលេខ ៣៧៦ ឆ្នាំ២០០៩)**

យោងតាមមាត្រា ១១នៃប្រកាសក្រសួងបរិស្ថានលេខ៣៧៦ ចុះនៅឆ្នាំ២០០៩ ការពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញរបស់ក្រសួង បរិស្ថានមានរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានពាក្យស្នើសុំពិនិត្យបរិស្ថាន។

ក្នុងករណីដែលមានការតម្រូវឱ្យកែសម្រួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានត្រូវការពេលក្នុងការពិនិត្យរបាយការណ៍៣០ថ្ងៃផ្សេងទៀត។

### ៣.១.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន

យោងតាមមាត្រា១៤នៃប្រកាសលេខ៣៧៦របស់ក្រសួងបរិស្ថាន នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានមានភារកិច្ចក្នុងការត្រួតពិនិត្យ អធិការកិច្ច និងតម្រូវឱ្យម្ចាស់គម្រោងអនុវត្តផែនការគ្រប់គ្រងបរិស្ថានក្នុងអំឡុងពេលសាងសង់ ប្រត្តិបត្តិការ និងជំហានបញ្ចប់ដូចអ្វីដែលបានចែងក្នុងរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប អនុម័តដោយក្រសួងបរិស្ថាន ។

ម្ចាស់គម្រោងត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយពេល៦ខែគិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថានបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យលេខ៧២របស់ក្រសួងបរិស្ថាន។

## ៣.២ ការចូលរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនតាមដំណាក់កាលខ្លះនៃដំណើរការ វ.ហ.ប ក្នុងប្រទេសកម្ពុជា

សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រួមទាំងគម្រោងផ្លូវថ្នល់ ដែលក្រសួងសាធារណការ និងដឹកជញ្ជូន ជាម្ចាស់គម្រោង គឺត្រូវចូលរួមក្នុងជំហានខ្លះនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា។

ដូចមានចែងក្នុងប្រកាសក្រសួងសាធារណការ និងដឹកជញ្ជូន លេខ២២៧ ឆ្នាំ២០១៦ ចែងថា ការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ត្រូវមានតួនាទី និងភារកិច្ច ចូលរួមពាក់ព័ន្ធនឹងការគាំពារឬការគិតគូរពីបរិស្ថាន និងសង្គម រួមបញ្ចូលទាំងការចូលរួមពាក់ព័ន្ធជំហានខ្លះនៃដំណើរការ វ.ហ.ប នៅក្នុងប្រទេសកម្ពុជាក្នុងនាមជាម្ចាស់គម្រោង។

ប្រសិនបើមានការបង្កើតអង្គភាពគ្រប់គ្រងគម្រោង (Project Management Unit) សម្រាប់គម្រោងផ្លូវថ្នល់ មន្ត្រីការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ត្រូវចូលរួមក្នុងអង្គភាពគ្រប់គ្រងគម្រោងនេះទៅលើបញ្ហាបរិស្ថាន និងសង្គម។

### ៣.២.១ ដំណាក់កាលរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ម្ចាស់គម្រោងត្រូវមានជំនាញបច្ចេកទេស និងគ្រប់គ្រងក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលក្រុមអ្នកជំនាញបច្ចេកទេសទាំងនោះត្រូវបានទទួលស្គាល់ដោយក្រសួងបរិស្ថាន។ ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យដែលមានជំនាញបច្ចេកទេសគ្រប់គ្រាន់ និងទទួលស្គាល់ដោយក្រសួង បរិស្ថាននឹងត្រូវបានជួល ប្រសិនបើមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មិនមានជំនាញបច្ចេកទេសគ្រប់គ្រាន់ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដូច្នេះក្រសួងសាធារណការ និងដឹកជញ្ជូនអាចរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានជំនួយបច្ចេកទេសពីក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប ឯករាជ្យ។

ចំពោះគម្រោងផ្លូវថ្នល់ អគ្គនាយកដ្ឋានដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោងនៃក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានអញ្ជើញឱ្យចូលរួមជាសាធារណៈ ដើម្បីប្រមូលមតិយោបល់សាធារណៈចូលក្នុងរបាយការណ៍ វ.ហ.ប ដែលរៀបចំឡើងដោយម្ចាស់គម្រោង។

អគ្គនាយកដ្ឋានដែលមានភារកិច្ចទទួលខុសត្រូវ ក្នុងការគ្រប់គ្រងគម្រោងនៅក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវផ្តល់ព័ត៌មាន និងទិន្នន័យជាក់លាក់ទៅឱ្យក្រុមហ៊ុនប្រឹក្សាឯករាជ្យ ដើម្បីដាក់បញ្ចូលទៅក្នុងផ្នែកពិពណ៌នាពីគម្រោងក្នុងរបាយការណ៍ វ.ហ.ប ប្រសិនបើមានការស្នើសុំពីក្រុមហ៊ុន។

### ៣.២.២ ដំណាក់កាលពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

គោលបំណងនៃការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាការវាយតម្លៃភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាន និងគុណភាពរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយនិងការកំណត់ពីភាពគ្រប់ជ្រុងជ្រោយពេញលេញនៃព័ត៌មាន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តចុងក្រោយក្នុងការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**១) ការពិនិត្យរបាយការណ៍ពង្រាងស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងក្រសួងសាធារណការ និងដឹកជញ្ជូន**

ដូចមានចែងក្នុងប្រកាសនៃក្រសួងសាធារណការ និងដឹកជញ្ជូន ការិយាល័យ បរិស្ថាន និងសង្គម មានភារកិច្ចទាក់ទងនឹងការងារបរិស្ថាន និងសង្គម ដូច្នេះក្រសួងពិនិត្យលើសេចក្តីព្រាងរបាយការណ៍ និងផ្តល់មតិយោបល់ផ្ទៃក្នុងចំណោមមន្ត្រីបច្ចេកទេសនៃក្រសួងសាធារណការ និងដឹកជញ្ជូនបន្ទាប់ពីក្រុមហ៊ុនប្រឹក្សាEIA ប្រគល់របាយការណ៍ទៅក្រសួងសាធារណការ និងដឹកជញ្ជូន។ បន្ទាប់ពីការពិនិត្យរបាយការណ៍ផ្ទៃក្នុងរួចរាល់ របាយការណ៍នឹងត្រូវផ្ញើទៅក្រសួងបរិស្ថាន។

**២) កិច្ចប្រជុំអន្តរក្រសួងពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បន្ទាប់ពីក្រសួងបរិស្ថានពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន និង ស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអន្តរក្រសួងក្នុងការពិនិត្យ និងផ្តល់មតិយោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ អគ្គនាយកដ្ឋានទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោង តំណាងឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវចាត់ទុកជាម្ចាស់គម្រោងនឹងចូលរួមក្នុងកិច្ចប្រជុំ និងឆ្លើយតបទៅនឹងសំនួរ និងការពិចារណាលើមតិយោបល់នៃកិច្ចប្រជុំផងដែរ ហើយមតិយោបល់ពីកិច្ចប្រជុំនេះនឹងត្រូវដាក់បញ្ចូលក្នុងរបាយការណ៍។ ទាំងនេះស្ថិតនៅក្នុងដំណាក់កាលពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ៣.២.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន និងផែនការអង្កេតតាមដានបរិស្ថាន មានគោលបំណង ដើម្បីបញ្ជាក់ពីប្រសិទ្ធភាពនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ក្នុងអំឡុងពេលសាងសង់ និងប្រត្តិបត្តិការបង្ហាញក្នុងដំណាក់កាលអង្កេតតាមដានបរិស្ថាន។

ទោះបីជាយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះមិនមានទិដ្ឋភាពផ្នែកច្បាប់ជាក់លាក់ណាមួយ បង្ហាញពីដំណាក់កាលអង្កេតតាមដានគម្រោងនៅប្រទេសកម្ពុជា។ ក្រសួងបរិស្ថានមានតម្រូវការមួយចំនួនសម្រាប់ម្ចាស់គម្រោង ត្រូវអនុវត្តក្នុងដំណាក់កាលអង្កេតតាមដានបរិស្ថាន ដូចខាងក្រោម៖

- ម្ចាស់គម្រោងត្រូវអនុវត្តសកម្មភាពរបស់ខ្លួន ដោយយោងតាមផែនការគ្រប់គ្រងបរិស្ថានដែលមានបញ្ជាក់នៅក្នុងរបាយការណ៍ក្នុងអំឡុងពេល៦ខែ បន្ទាប់ពីក្រសួងបរិស្ថានអនុម័តលើរបាយការណ៍ វ.ហ.ប។
- ម្ចាស់គម្រោងត្រូវបញ្ជូនរបាយការណ៍អង្កេតតាមដានបរិស្ថាន ទៅឱ្យក្រសួងបរិស្ថានជារៀងរាល់៣ទៅ៦ខែម្តង ដូចដែលមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចាត់តាំងនាយកដ្ឋានដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ឱ្យអនុវត្តដំណើរការអង្កេតតាមដានបរិស្ថានដូចខាងក្រោម៖

- អនុវត្តសកម្មភាពអង្កេតតាមដានដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន។
- រៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន។

ក្រសួងសាធារណការ និងដឹកជញ្ជូន ចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមួយស្ថាប័នពាក់ព័ន្ធដូចតារាង៣.១ខាងក្រោម។

**តារាង៣.១ ដំណាក់កាលនៃដំណើរការ វ.ហ.ប ដែលចូលរួមដោយក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងគម្រោងវិស័យផ្លូវថ្នល់**

| ដំណាក់កាល | ស្ថាប័នទទួលខុសត្រូវ/អង្គភាពពាក់ព័ន្ធ | ការអនុវត្ត |
|---|---|---|
| ការរៀបចំពិពណ៌នាពីគម្រោង | - អគ្គនាយកដ្ឋានទទួលខុសត្រូវគ្រប់គ្រងគម្រោងក្នុងក្រសួង<br>- ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប | - អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងក្នុងក្រសួងត្រូវជួលក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប និងត្រូវផ្តល់ព័ត៌មាន និងទិន្នន័យទាក់ទងគម្រោងទៅឱ្យក្រុមហ៊ុន ទីប្រឹក្សា វ.ហ.ប នៅពេលមានការស្នើសុំ |
| ការចុះមូលដ្ឋានដោយក្រសួងសាធារណការ និងដឹកជញ្ជូន | - ការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ និងក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប | - ការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ចុះមូលដ្ឋានជាមួយនិងក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប និងស្ថាប័នដែលពាក់ព័ន្ធ ប្រសិនបើចាំបាច់ |
| ការកំណត់វិសាលភាពគម្រោង | - ក្រសួងបរិស្ថាន<br>- អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងក្នុងក្រសួង | - ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប រៀបចំលក្ខខណ្ឌការងារ (ToR) |

| | | |
|---|---|---|
| | - ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប និង<br>- ភាគីពាក់ព័ន្ធដទៃទៀត | - ក្រសួងបរិស្ថានពិនិត្យលក្ខខណ្ឌការងារ (ToR) និងអនុម័ត<br>- អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងត្រូវផ្តល់ព័ត៌មានដល់ភាគីដែលពាក់ព័ន្ធ |
| ការពិនិត្យរបាយការណ៍ពង្រាង វ.ហ.ប ក្នុងចំណោមមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន (ផ្ទៃក្នុង) | - ការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ និង<br>- ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប | - ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប រៀបចំពង្រាងរបាយការណ៍ វ.ហ.ប<br>- ការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការពិនិត្យរបាយការណ៍ពង្រាងផ្ទៃក្នុងក្រសួង មុននឹងផ្ញើជូនក្រសួង បរិស្ថានពិនិត្យ និងអនុម័តលើរបាយការណ៍ |
| កិច្ចប្រជុំអន្តរក្រសួង | - ក្រសួងបរិស្ថាន<br>- អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងក្នុងក្រសួង<br>- ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប និង<br>- ភាគីពាក់ព័ន្ធដទៃទៀត | - ក្រសួងបរិស្ថានជាប្រធាននៃ អង្គប្រជុំ<br>- អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងក្នុងក្រសួង ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប ចូលរួមក្នុងកិច្ចប្រជុំ ដើម្បីឆ្លើយតបនឹងសំណួរប្រសិនបើមាន |
| ដំណាក់កាលអង្កេតតាមដានបរិស្ថាន | - អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងក្នុងក្រសួង និង<br>- ក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប | - អគ្គនាយកដ្ឋានទទួលបន្ទុកគ្រប់គ្រងគម្រោងអនុវត្តផែនការគ្រប់គ្រងបរិស្ថានក្រោមកិច្ច សហការជាមួយម្ចាស់កិច្ចសន្យាសាងសង់ និងរៀបចំកិច្ចប្រជុំ ជាមួយអ្នកពាក់ព័ន្ធដើម្បីរៀបចំ របាយការណ៍អង្កេតតាមដាន បរិស្ថានក្រោមជំនួយបច្ចេកទេសពីក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប |

# ជំពូកទី៤ វិធីសាស្ត្រចូលរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងដំណើរការ វ.ហ.ប នៅប្រទេសកម្ពុជា

## ៤.១ ដំណាក់កាលរៀបចំរបាយការណ៍ វ.ហ.ប

### ៤.១.១ មាតិកានៃរបាយការណ៍ វ.ហ.ប

យោងតាមប្រកាសលេខ៣៧៦របស់ក្រសួងបរិស្ថាន មាតិកានៃរបាយការណ៍ វ.ហ.ប មានដូចខាងក្រោមៈ

**១) ខ្លឹមសារសង្ខេប**

នៅក្នុងផ្នែកនេះ ត្រូវសង្ខេបនូវខ្លឹមសារសំខាន់ៗនៃរបាយការណ៍ទាំងមូល ដូចជាគោលបំណងសកម្មភាពគម្រោង ធនធានបរិស្ថានដែលមានស្រាប់ លទ្ធផលនៃកិច្ចប្រជុំជាសាធារណៈ ការកំណត់ហេតុប៉ះពាល់បរិស្ថាន និងសង្គមព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយ ផែនការគ្រប់គ្រងបរិស្ថានសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន។

**២) ជំពូកទី១ សេចក្តីផ្តើម**

- លក្ខណៈទូទៅនៃគម្រោង ត្រូវរៀបចំដោយសង្ខេបពីប្រវត្តិ និងមូលហេតុដែលគម្រោងត្រូវបានបង្កើតឡើងព្រមទាំងបង្ហាញស្ថានភាពទូទៅនៃតំបន់គម្រោង។
- គោលបំណងនៃការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- វិធីសាស្រ្ត និងទំហំនៃការសិក្សា ត្រង់ចំណុចត្រូវរៀបរាប់អំពីតម្រូវការព័ត៌មាន ទិន្នន័យ វិធីសាស្រ្តប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។ ក្នុងករណីការរៀបចំរបាយការណ៍ វ.ហ.ប ម្ចាស់គម្រោងត្រូវសិក្សាលម្អិតនូវវិធីសាស្រ្ត និងរៀបចំជំពូកថ្មីមួយដាច់ដោយឡែក។

**៣) ជំពូកទី២ វិធីសាស្រ្តនៃការវាយតម្លៃ**

ជំពូកនេះត្រូវមានដាច់ដោយឡែក នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។ ព័ត៌មានលម្អិតស្តីពីវិធីសាស្រ្តវាយតម្លៃត្រូវរៀបរាប់នៅក្នុងជំពូកនេះ។

**៤) ជំពូកទី៣ ក្របខ័ណ្ឌច្បាប់**

ក្នុងក្របខណ្ឌច្បាប់ ម្ចាស់គម្រោងត្រូវពិពណ៌នាអំពីច្បាប់ អនុក្រឹត្យ និងគោលនយោបាយនានាដែលមានការពាក់ព័ន្ធទៅនឹងប្រភេទគម្រោងដែលនឹងត្រូវអនុវត្ត។ រាល់ខ្លឹមសារមាត្រានៃច្បាប់ និងបទបញ្ញត្តិ ដូចបានរៀបរាប់ខាងលើ ត្រូវតែមានការពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងគម្រោងអភិវឌ្ឍន៍។

បទបញ្ញត្តិ និងស្តង់ដាបរិស្ថាន ដែលត្រូវយកមកអនុវត្តក្នុងគម្រោង ត្រូវតែមានឯកសារយោងត្រឹមត្រូវ។

**៥) ជំពូកទី៤ ការពិពណ៌នាអំពីគម្រោង**

នៅក្នុងជំពូកនេះត្រូវរៀបរាប់ឱ្យបានលម្អិត ដូចមានចែងនៅក្នុងរបាយការណ៍សិក្សាបុរេសមិទ្ធិលទ្ធភាព

ឬរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព ឬផែនការមេរបស់ក្រុមហ៊ុន ដែលមានចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុន / គម្រោង
- ទីតាំងគម្រោង (ត្រូវភ្ជាប់មកជាមួយនូវផែនទីរដ្ឋបាលតំបន់ និងទីតាំងគម្រោង)
- ប្រភេទ/ទំហំគម្រោង និងពេលវេលានៃសកម្មភាពគម្រោង (ដំណាក់កាលមុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គម្រោង)
- ផែនការសកម្មភាពការងារ ឧទាហរណ៍ (១) -ប្រភព និង បរិមាណវត្ថុធាតុដើមដែលត្រូវប្រើប្រាស់ (២) -តម្រូវការគ្រឿងចក្រ (៣) -តម្រូវការកម្លាំងពលកម្មក្នុងស្រុក និងក្រៅប្រទេស (៤) -បរិមាណផលិតផលសម្រេច (៥) -ចំណូល-ចំណាយ (៦) - ខ្សែ សង្វាក់ផលិតកម្ម (៧) -ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ។ល។
- កម្មវិធីសកម្មភាពការងារគម្រោង។

**៦) ជំពូកទី៥ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់**

ជំពូកនេះត្រូវពិពណ៌នាអំពីធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម (ទិន្នន័យដែលបានសិក្សាកន្លងមក និង ទិន្នន័យថ្មី) នៅក្នុងនិងជុំវិញតំបន់គម្រោង រួមមាន៖

**ក. បរិស្ថានធម្មជាតិ**

**ធនធានរូបសាស្ត្រ**

- ដី៖ ភូគព្ភសាស្ត្រ សណ្ឋានដី/ឋានលេខា ចំណាត់ថ្នាក់ប្រភេទដី ការហូរច្រោះ និងកំណកដី ។ ក្នុងករណីរៀបចំរបាយការណ៍ វ.ហ.ប ត្រូវសិក្សាលម្អិតបន្ថែមពីការរញ្ជួយដី ភូគព្ភសាស្ត្រ (ធនធានរ៉ែ បើសិនជាមាន)

- អាកាសធាតុ៖ សីតុណ្ហភាព របបទឹកភ្លៀង និងល្បឿនខ្យល់ សម្ពាធខ្យល់ ទិសខ្យល់ និងសំណើម។

- គុណភាពខ្យល់ (គុណភាពខ្យល់នៅជុំវិញតំបន់គម្រោង) កម្រិតសំឡេង និងរំញ័រ (កម្រិតសំឡេងក្នុងតំបន់គម្រោង)។

- ជលសាស្ត្រ៖ បរិមាណ និងគុណភាពទឹកលើដី ក្រោមដី (ការវិភាគគុណភាពទឹកក្នុងតំបន់គម្រោង)ធារទឹក និងចរន្តទឹក។

**ធនធានជីវសាស្ត្រ**

- ព្រៃឈើ៖ ផ្ទៃដីព្រៃឈើ ប្រភេទគម្របព្រៃឈើ និងចំណាត់ថ្នាក់ប្រភេទឈើ

- ប្រភេទសត្វព្រៃ ប្រភេទសត្វកម្រ ប្រភេទជិតផុតពូជ និងការបម្លាស់ទី

- ទីជម្រក

- ជីវៈចម្រុះ និងជីវសាស្ត្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី

- ប្រព័ន្ធ ដីសើម(ភ្ជាប់មកជាមួយនូវផែនទីពាក់ព័ន្ធ)។

**ខ. ធនធានសេដ្ឋកិច្ច សង្គម**

- ប្រជាសាស្ត្រ និងការតាំងទីលំនៅ
- ស្ថានភាពសេដ្ឋកិច្ច មុខរបរ ប្រាក់ចំណូល (ប្រភពចំណូលចម្បង និងបន្ទាប់បន្សំ)
- ការប្រើប្រាស់ដី
- ការប្រើប្រាស់ទឹក
- ការប្រើប្រាស់ថាមពល
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- ការអប់រំ
- សុខភាព និងសុខុមាលភាពសាធារណៈ
- សម្បត្តិវប្បធម៌ សំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ វត្តអារាម ទំនៀមទម្លាប់ ជនជាតិដើម ឬជនជាតិភាគតិច
- តំបន់ទេសចរណ៍

**៧) ជំពូកទី៦ ការចូលរួមពីសាធារណជន**

ក្នុងជំពូកនេះត្រូវពិពណ៌នាលម្អិតលទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ លើចំណុចមួយចំនួនដូចខាងក្រោម៖

**ក. សេចក្តីផ្តើម**

**ខ. ការចូលរួមរបស់សាធារណៈ**

- ការផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋានពីគម្រោងអភិវឌ្ឍន៍
- ការផ្តល់យោបល់របស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន
- ការផ្តល់យោបល់របស់តំណាងអង្គភាពពាក់ព័ន្ធ
- ការស្ទង់មតិជាមួយប្រជាជនមូលដ្ឋានដែលរងនូវការប៉ះពាល់

**គ. សន្និដ្ឋានរួមលើលទ្ធផលពិគ្រោះយោបល់។**

**៨) ជំពូកទី៧ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ**

ក្នុងជំពូកនេះ ត្រូវពិពណ៌នាពីហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គមអវិជ្ជមាន និងវិជ្ជមានសំខាន់ៗដែលអាចកើតឡើងពីសកម្មភាពគម្រោងដូចជា៖

**ក.** ពិពណ៌នាពីហេតុប៉ះពាល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គមអវិជ្ជមាននៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង (មុនសាងសង់ និង សាងសង់) ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយ។

**ខ.** សង្ខេបចំណុច ស្តីពីទំហំនៃហេតុប៉ះពាល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយនៅក្នុងតារាងសង្ខេបដូចមានគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២

**គ.** ករណីរៀបចំវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវសិក្សាលម្អិតបន្ថែមពីបណ្តុំនៃហេតុប៉ះពាល់។

**ឃ.** ពិពណ៌នាពីហេតុប៉ះពាល់អវិជ្ជមានលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម ។

### ៩) ជំពូក៨ ផែនការគ្រប់គ្រងបរិស្ថាន (EMP)

នៅក្នុងផ្នែកនេះ ម្ចាស់គម្រោងចាំបាច់ត្រូវមានមូលនិធិគ្រប់គ្រាន់សម្រាប់កិច្ចការពារបរិស្ថាន និងបង្កើតផ្នែក/ក្រុមមួយ ដែលមានបុគ្គលិកជំនាញប្រកបដោយសមត្ថភាព ឧបករណ៍វិធីសាស្ត្រ និងកាលវិភាគត្រឹមត្រូវសម្រាប់ត្រួតពិនិត្យគុណភាពបរិស្ថានដោយសហការឱ្យបានជិតស្និទ្ធជាមួយក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរបស់គម្រោងទៅលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច សង្គម។

ផែនការគ្រប់គ្រងបរិស្ថាននេះរួមមានៈ

- ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ
- កម្មវិធីបណ្តុះបណ្តាល
- កម្មវិធីត្រួតពិនិត្យបរិស្ថាន ក្នុងដំណាក់កាលសាងសង់ ប្រត្តិបត្តិគម្រោង និងបញ្ចប់គម្រោង ដែលក្នុងនោះម្ចាស់គម្រោងត្រូវបញ្ជាក់ពី ១)ស្ថាប័នត្រួតពិនិត្យ សម្រាប់ការអង្កេតតាមដានគម្រោង ២)កំណត់នូវប៉ារ៉ាម៉ែត្រដែលត្រូវត្រួតពិនិត្យ ៣)វិធីសាស្ត្រក្នុងការត្រួតពិនិត្យ ៤)បទដ្ឋានបរិស្ថាន ឬ គោលការណ៍ណែនាំណាមួយដែលត្រូវយកមកអនុវត្តក្នុងការត្រួតពិនិត្យ ៥)កម្មវិធី និងខួបដែលត្រូវត្រួតពិនិត្យការវាយតម្លៃ លទ្ធផលនៃការត្រួតពិនិត្យដោយម្ចាស់គម្រោងផ្ទាល់ ៦)ការរៀបចំរបាយការណ៍ប្រចាំត្រីមាស ដើម្បីផ្ញើជូនក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។

### ១០) ជំពូកទី៩ ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

ក្នុងករណីរៀបចំវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ម្ចាស់គម្រោងត្រូវពិពណ៌នាអំពីផលចំណេញដែលទទួលបានពីគម្រោង ដោយប្រៀបធៀបទៅនឹងតម្លៃ និងទំហំនៃការខូចខាតបរិស្ថានដែលកើតមានឡើងពីសកម្មភាពគម្រោង។

### ១១) ជំពូកទី១០ សន្និដ្ឋាន និងអនុសាសន៍

ក្នុងផ្នែកនេះម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាធានាអះអាង និងទទួលខុសត្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងលើកឡើងនូវអនុសាសន៍ដែលពាក់ព័ន្ធនឹងគម្រោង។

ដូចនេះក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវអនុវត្តតាមមាតិកាទូទៅក្នុងការរៀបចំរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ដូចមានចែងក្នុងឧបសម្ព័ន្ធ១នៃប្រកាសរបស់ក្រសួងបរិស្ថានលេខ៣៧៦ ឬក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងនាមជាម្ចាស់គម្រោងត្រូវអនុវត្តតាមការណែនាំ ឬបទបញ្ញត្តិដែលរៀបចំដោយក្រសួងបរិស្ថាន។ ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចែករំលែកព័ត៌មានអំពីគម្រោងទៅឱ្យក្រុមហ៊ុនទីប្រឹក្សា វ.ហ.ប ប្រសិនបើមានការស្នើសុំពីក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប។

## ៤.២ ដំណាក់កាលពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប

### ៤.២.១ សេចក្តីផ្តើមនៃការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប

យោងតាម ឯកសារបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (UNEP, ២០០២) គោលបំណងគន្លឹះនៃការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប មានដូចខាងក្រោម៖

- វាយតម្លៃគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍
- ទទួលយកមតិយោបល់សាធារណៈ
- ផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ថារបាយការណ៍មានព័ត៌មានគ្រប់គ្រាន់ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត
- កង្វះខាតត្រូវបានដោះស្រាយ មុននឹងបញ្ជូនរបាយការណ៍ដើម្បីពិនិត្យ និងសម្រេច។

ជាទូទៅ ការកំណត់ភាពកង្វះខាតនៃរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប អាចធ្វើឡើងដោយការផ្ទៀងផ្ទាត់នឹងលក្ខខណ្ឌការងារ(ToR)នៃការសិក្សា វ.ហ.ប.ដ/វ.ហ.ប និងរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ដែលមានភាពប្រហាក់ប្រហែលគ្នាសម្រាប់ធ្វើការប្រៀបធៀប។

ម្យ៉ាងទៀត ប្រសិនបើមានច្បាប់និងបទបញ្ញត្តិផ្សេងៗដែលទាក់ទងដោយផ្ទាល់នឹងគម្រោង ច្បាប់និងបទបញ្ញត្តិទាំងនោះ ត្រូវប្រើប្រាស់ជាឯកសារយោង ដើម្បីបញ្ជាក់ពីគុណភាពឬភាពត្រឹមត្រូវនៃរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ។ បទដ្ឋាន ឬលក្ខខណ្ឌរបស់ដៃគូអភិវឌ្ឍន៍ត្រូវគោរពតាមប្រសិនបើគម្រោងនោះទទួលជំនួយពីដៃគូអភិវឌ្ឍន៍។

### ៤.២.២ វិធីសាស្ត្រក្នុងការពិនិត្យរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប

ជាដំបូង ធាតុដែលត្រូវពិនិត្យក្នុងរបាយការណ៍មានដូចជា៖

- របាយការណ៍ វ.ហ.ប.ដ/វ.ហ.ប គោរពតាមលក្ខខណ្ឌការងារ(ToR)យ៉ាងពេញលេញ
- រាល់ខ្លឹមសារនៅក្នុងរបាយការណ៍ វ.ហ.ប.ដ/វ.ហ.ប ត្រូវមានភាពទាក់ទងគ្នាពីផ្នែកមួយទៅផ្នែកមួយ
- របាយការណ៍គួរតែងាយស្រួលអាន និងយល់សម្រាប់មន្ត្រីជំនាញនៅក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធដទៃទៀត។

សេចក្តីសង្ខេប គួរត្រូវពិនិត្យ និងត្រូវមានខ្លឹមសារដូចខាងក្រោម៖

- គោលបំណងគម្រោង
- សកម្មភាពគម្រោង
- ធនធានបរិស្ថានដែលមានស្រាប់
- លទ្ធផលនៃការពិគ្រោះយោបល់សាធារណៈ
- វិសាលភាពនៃហេតុប៉ះពាល់លើបរិស្ថាន និងសង្គម និងវិធានការកាត់បន្ថយហេតុប៉ះពាល់
- ផែនការគ្រប់គ្រងបរិស្ថាន
- សន្និដ្ឋាន និងអនុសាសន៍។

ចំណុចសំខាន់ៗដែលត្រូវពិនិត្យមើលនៅក្នុងជំពូកនីមួយៗ មានបង្ហាញដូចខាងក្រោម៖

**ក. សេចក្តីផ្តើម**

នៅក្នុងផ្នែកនេះត្រូវមានចំណុចសំខាន់ៗដូចខាងក្រោម៖

- ទិដ្ឋភាពទូទៅនៃគម្រោង (សេចក្តីសង្ខេបនៃប្រវត្តិគម្រោង មូលហេតុនៃការបង្កើតគម្រោង និងស្ថានភាពទូទៅនៃទីតាំងគម្រោង)
- គោលបំណងនៃការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន
- វិធីសាស្រ្ត និងទំហំនៃការសិក្សាៈ ត្រង់ចំណុចនេះត្រូវរៀបរាប់អំពីតម្រូវការព័ត៌មាន ទិន្នន័យ វិធីសាស្រ្តប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ។

**ខ. វិធីសាស្រ្តវាយតម្លៃ**

ធាតុផ្សំរួមទាំងផែនទីដែលត្រូវមាននៅក្នុងផ្នែកនេះ មានដូចខាងក្រោម៖

- ប្រភេទទិន្នន័យបឋម និងបន្ទាប់បន្សំអ្វីខ្លះដែលត្រូវប្រមូល
- ប្រភេទវិធីសាស្រ្ត ឬម៉ូឌែលអ្វីខ្លះដែលត្រូវប្រើសម្រាប់វិភាគ និងព្យាករណ៍ហេតុប៉ះពាល់
- ប្រភេទវិធានការកាត់បន្ថយហេតុប៉ះពាល់អ្វីខ្លះដែលត្រូវគិតគូរ

សម្រាប់គម្រោងសាងសង់ផ្លូវថ្នល់ ការព្យាករណ៍ហេតុប៉ះពាល់ត្រូវធ្វើឡើងដោយផ្អែកលើការវិភាគបែបបរិមាណវិស័យឱ្យបានកាន់តែច្រើនកាន់តែល្អសម្រាប់ វាយតម្លៃគុណភាពខ្យល់ សំលេង និងរំញ័រ។

**គ. ក្របខ័ណ្ឌច្បាប់**

របាយការណ៍ វ.ហ.ប គួរបញ្ចូល ច្បាប់ បទបញ្ញត្តិ និងគោលនយោបាយដែលទាក់ទងដូចខាងក្រោម៖

- ច្បាប់ អនុក្រឹត្យ គោលនយោបាយទាក់ទងនឹងសកម្មភាពគម្រោង
- ផែនការ និងគោលនយោបាយបរិស្ថានទាក់ទងនឹងសកម្មភាពគម្រោង
- ស្តង់ដារ និងបទបញ្ញត្តិបរិស្ថាននៅក្នុងប្រទេសកម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងសកម្មភាពគម្រោង។

**ឃ. ការពិពណ៌នាអំពីគម្រោង**

ធាតុផ្សំរួមទាំងផែនទីដែលត្រូវមាននៅក្នុងផ្នែកនេះ មានដូចខាងក្រោម៖

- ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុន / គម្រោង
- ទីតាំងគម្រោង (ត្រូវភ្ជាប់មកជាមួយនូវផែនទីរដ្ឋបាលតំបន់ និងទីតាំងគម្រោង)
- ប្រភេទ/ទំហំគម្រោង និងពេលវេលានៃសកម្មភាពគម្រោង (ដំណាក់កាលមុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គម្រោង)

សម្រាប់គម្រោងសាងសង់ផ្លូវថ្នល់ ផែនការសាងសង់ជារួម និងការងារខាងក្រៅការដ្ឋានដូចជាទីតាំងនៃជំរុំសាងសង់ ផ្លូវចូល (Access road) ទីតាំងយករ៉ែ (ថ្ម)គួរត្រូវបានរាប់បញ្ចូល។

### ង. ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

ធាតុផ្សំ រួមទាំងផែនទីដែលត្រូវមាននៅក្នុងផ្នែកនេះ មានដូចខាងក្រោម៖

- ធនធានរូបសាស្ត្រ សម្រាប់ជា ទិន្នន័យគោលនៅក្នុងតំបន់គម្រោង
- ធនធានជីវសាស្ត្រ សម្រាប់ជា ទិន្នន័យគោលនៅក្នុងតំបន់គម្រោង
- ធនធានសេដ្ឋកិច្ច សង្គម សម្រាប់ជា ទិន្នន័យគោលនៅក្នុងតំបន់គម្រោង

តំបន់គម្រោងរួមបញ្ចូល ទីតាំងគម្រោង និងតំបន់ជុំវិញទីតាំងគម្រោង ដែលប៉ះពាល់ដោយផ្ទាល់ ទៅលើបរិស្ថាន និងសង្គមបណ្តាលមកពីសកម្មភាពរបស់គម្រោង។

វាជាការសំខាន់ដែលទីតាំងគម្រោង និងហេតុប៉ះពាល់បរិស្ថាន និងសង្គមបណ្តាលមកពីគម្រោងត្រូវបានដៅឬបង្ហាញនៅលើផែនទីឱ្យបានកាន់តែច្រើនកាន់តែប្រសើរ ដើម្បីងាយស្រួលយល់ដឹងពីទំនាក់ទំនងរបស់វា។

សម្រាប់គម្រោងសាងសង់ផ្លូវថ្នល់ ទីតាំងគម្រោងគួររាប់បញ្ចូលទីតាំងសាងសង់ ទីតាំងជំនួសផ្លូវចូល និងរាល់ទីតាំងដែលទាក់ទងនឹងគម្រោងទាំងអស់។ តារាង៤.១ បង្ហាញពីទិន្នន័យ/ព័ត៌មានចាំបាច់សំខាន់ៗទាក់ទងនឹងបរិស្ថាន ដែលមានស្រាប់នៅក្នុងតំបន់គម្រោង។

**តារាង ៤.១ ទិន្នន័យ និងព័ត៌មានចាំបាច់សំខាន់ៗទាក់ទងនឹងបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោងនៃ វិស័យផ្លូវថ្នល់**

| ធាតុផ្សំ | ទិន្នន័យនិងព័ត៌មានចាំបាច់ |
|---|---|
| **៥.១ ធនធានបរិស្ថានធម្មជាតិ**<br>**៥.១.១ ធនធានរូបសាស្ត្រ** | |
| ដី | លក្ខណៈនៃសណ្ឋានដី និងភូមិសាស្ត្រ (ផែនទីសណ្ឋានដី និងភូគព្ភសាស្ត្រ) |
| អាកាសធាតុ | ព័ត៌មានលម្អិតពីលក្ខខណ្ឌឧតុនិយមនៅទីតាំងគម្រោង (សីតុណ្ហភាព សំណើម របបទឹកភ្លៀង ទិសនិងល្បឿនខ្យល់) |
| គុណភាពខ្យល់ | ទិន្នន័យនៃការបំពុលខ្យល់នាពេលបច្ចុប្បន្ន (TSP, CO, NO2, SO2, PB...។ល។) |
| សំឡេង និងរំញ័រ | កម្រិតរំញ័រ និងសំឡេងរំខាននាពេលបច្ចុប្បន្ន |
| ជលសាស្ត្រ | លក្ខណៈលំហូរទឹកទន្លេ និងបឹង<br>ទិន្នន័យពីលក្ខណៈទឹកក្រោមដី និងអណ្តូង |
| គុណភាពទឹក | ទិន្នន័យគុណភាពទឹកលើដីនិងក្រោមដីនាពេលបច្ចុប្បន្ន (pH, TSS, DO, BOD, ប្រេងឬខ្លាញ់ ,...។ល។) |
| **៥.១.២ ធនធានជីវសាស្ត្រ** | |
| ព្រៃឈើ | ផែនទីរុក្ខជាតិនាពេលបច្ចុប្បន្ន និងបញ្ជីប្រភេទរុក្ខជាតិមានតម្លៃ |
| សត្វព្រៃ | ផែនទីសត្វនាពេលបច្ចុប្បន្ន និងបញ្ជីប្រភេទសត្វមានតម្លៃ |
| ជម្រក | ផែនទីជម្រកសត្វដែលត្រូវការពារ និងតំបន់ការពារ |

| | |
|---|---|
| ជីវៈចម្រុះ | ផែនទីតំបន់ជីវចម្រុះសំខាន់ៗនិងតំបន់ការពារ |
| តំបន់ដីសើម | ផែនទីប្រព័ន្ធតំបន់ដីសើម |
| **៥.២ បរិស្ថានសេដ្ឋកិច្ចសង្គម** | |
| ប្រជាសាស្ត្រ និងលំនៅដ្ឋាន | ស្ថិតិប្រជាជនក្នុងតំបន់ និងផែនទីលំនៅដ្ឋាន |
| ស្ថានភាពសេដ្ឋកិច្ច | ការងារ សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ ស្ថិតិពីប្រាក់ចំណូល |
| ការប្រើប្រាស់ដី | ផែនទី និងផែនការប្រើប្រាស់ដី |
| ការប្រើប្រាស់ទឹក | សិទ្ធិស្របច្បាប់ និងសិទ្ធិបែបប្រពៃណី |
| ការប្រើប្រាស់ថាមពល | ប្រភេទនិងចំនួននៃការប្រើប្រាស់ថាមពល |
| ហេដ្ឋារចនាសម្ព័ន្ធ | បណ្តាញគមនាគមន៍ និងបណ្តាញបរិក្ខាតាមដងផ្លូវ |
| ការអប់រំ | អត្រានៃអ្នកចូលរៀន |
| សុខភាពសាធារណៈ | ស្ថិតិនៃជំងឺឆ្លង |
| បេតិកភណ្ឌវប្បធម៌ | បញ្ជី និងផែនទីបេតិកភណ្ឌប្រវត្តិសាស្ត្រ និងវប្បធម៌ |
| តំបន់ទេសចរណ៍ | បញ្ជី និងផែនទីតំបន់គោលដៅទេសចរណ៍ |

### ច. ការចូលរួមពីសាធារណជន

ធាតុផ្សំដែលត្រូវមាននៅក្នុងផ្នែកនេះមានដូចជាៈ

- សកម្មភាពផ្សព្វផ្សាយអំពីគម្រោងដោយម្ចាស់គម្រោងទៅដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋានដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល។
- មតិយោបល់ពីម្ចាស់គម្រោង នាយកដ្ឋាន ស្ថាប័ន ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- មតិយោបល់ពីអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ (NGOs)
- លទ្ធផលនៃការពិភាក្សាជាមួយសហគមន៍មូលដ្ឋាន

### ឆ. ហេតុប៉ះពាល់ និងវិធានការកាត់បន្ថយ

ធាតុផ្សំដែលត្រូវមាននៅផ្នែកនេះមានដូចជាៈ

- ពិពណ៌នាពីហេតុប៉ះពាល់ជាអវិជ្ជមានលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម នៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង (រចនា និង សាងសង់)ប្រតិបត្តិ និងបញ្ចប់គម្រោងព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយ
- បណ្តុំនៃហេតុប៉ះពាល់
- តារាងសង្ខេប (scoping matrix) ពីវិសាលភាពនៃហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងវិធានការកាត់បន្ថយ
- ពិពណ៌នាពីហេតុប៉ះពាល់វិជ្ជមានលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម ។

រាល់ហេតុប៉ះពាល់ទាំងអវិជ្ជមាន និងវិជ្ជមានសំខាន់ៗរួមទាំងតំបន់ដែលងាយរងគ្រោះត្រូវមានបង្ហាញយ៉ាងច្បាស់ក្នុងផ្នែកនេះ។ ម្យ៉ាងទៀត វិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ទាំងអស់ ត្រូវរៀបរាប់ផងដែរ។

ធាតុផ្សំសំខាន់ៗដែលត្រូវមាននៅក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់ ត្រូវបានរៀបរាប់ដូចខាងក្រោម៖

- វិធានការកាត់បន្ថយហេតុប៉ះពាល់ទៅលើផលប៉ះពាល់សំខាន់ៗត្រូវបានរៀបចំគ្រប់គ្រាន់
- សំណងលើ ការផ្លាស់ទីលំនៅ និងការទិញដី ឬអចលនទ្រព្យផ្សេងៗ ត្រូវបានគិតគូរយ៉ាងម៉ត់ចត់
- ផលប៉ះពាល់ធ្ងន់ធ្ងរដែលមិនអាចជៀសផុត ឬកាត់បន្ថយត្រូវបានពិពណ៌នា
- វិធានការគាំទ្រការកាត់បន្ថយហេតុប៉ះពាល់ដែលពង្រឹងផលប៉ះពាល់វិជ្ជមាន ត្រូវបានរៀបចំឡើង
- បទពិសោធន៍ស្រដៀងគ្នាក្នុងពេលអតីតកាល ត្រូវបានយកមកប្រើប្រាស់នៅក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់
- វិធានការគាំទ្រ និងកាត់បន្ថយហេតុប៉ះពាល់ត្រូវមានលក្ខណៈបែបបច្ចេកទេស និងវិទ្យាសាស្ត្រត្រឹមត្រូវ។

ឧទាហរណ៍សំខាន់មួយចំនួននៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងផ្លូវថ្នល់ត្រូវបានរៀបរាប់ក្នុងតារាង ៤.២ខាងក្រោម។

**តារាង ៤.២ ឧទាហរណ៍សំខាន់នៃវិធានការកាត់បន្ថយហេតុប៉ះពាល់សម្រាប់គម្រោងផ្លូវថ្នល់**

| សមាសភាព | ឧទាហរណ៍សំខាន់នៃវិធានការកាត់បន្ថយហេតុប៉ះពាល់ |
|---|---|
| កាត់បន្ថយផលប៉ះពាល់ទៅលើដី | • ការជៀសវាងផ្លូវដែលកាត់តំបន់ងាយរងគ្រោះ (ឧ.តំបន់ការពារធនធានធម្មជាតិ តំបន់ជម្រាលជាដើម)<br>• ការសង់សំណង់ការពារ (ឧ.Gabions ជាដើម) |
| ការការពារ ឬ<br>កាត់បន្ថយការបំពុលខ្យល់(ធូលី) | • ការបាញ់ទឹកស្រោច និងការគ្របសម្ភារសំណង់ក្នុងពេលធ្វើដំណើរឱ្យបានត្រឹមត្រូវ<br>• ការគ្រប់គ្រងល្បឿនរថយន្តដែលដឹកសម្ភារៈ |
| ការការពារ ឬ<br>កាត់បន្ថយសំឡេងរំខាន | • ការបង្កើតឱ្យមានផ្លូវវាងដើម្បីជៀសវាងពីតំបន់ដែលរងប៉ះពាល់ដោយសារសំឡេង<br>• គ្រប់គ្រងពេលវេលាសាងសង់នៅតំបន់ទីប្រជុំជនដូចជាសាលារៀន មន្ទីរពេទ្យ លំនៅដ្ឋាន |
| ការការពារជលសាស្ត្រ | • ការសាងសង់គន្លងផ្លូវជៀសវាងការធ្វើឱ្យប្រែប្រួលលំហូរទឹក ជាអប្បបរមា<br>• ការគ្រប់គ្រងល្បឿនទឹកហូរដោយការដាំស្មៅ និងឧបករណ៍ផ្សេងទៀតក្នុងខ្សែទឹក |
| កាត់បន្ថយសំណល់ពីការដ្ឋានសាងសង់ | • រៀបចំ និងអនុវត្តផែនការគ្រប់គ្រងសំណល់ពីការដ្ឋានឱ្យបានត្រឹមត្រូវ<br>• គ្រប់គ្រងកន្លែងយកថ្មឱ្យបានត្រឹមត្រូវ |
| ការការពារជីវៈចម្រុះ (ប្រព័ន្ធអេកូឡូស៊ី) | • ជៀសវាងផ្លូវដែលឆ្លងកាត់តំបន់អេកូឡូស៊ីរសើប<br>• តំបន់ទ្រនាប់ដែលការពារប្រព័ន្ធអេកូឡូស៊ីត្រូវបានថែរក្សានៅតាមដីចំណីផ្លូវ |

| | |
|---|---|
| កាត់បន្ថយផលប៉ះពាល់ទៅលើ បរិស្ថានសេដ្ឋកិច្ចសង្គម | • ប្រសិនបើមានការជម្លៀសលំនៅដ្ឋាន ការទូទាត់សំណង និងជំនួយទ្រទ្រង់ជីវភាព គួរត្រូវមានភាពសមរម្យ<br>• ចៀសវាងការធ្វើឱ្យមានការបែងចែក សហគមន៍ក្នុងដំណាក់កាលរចនាគម្រោងផ្លូវថ្នល់ |
| កាត់បន្ថយជំលោះរវាងកម្មករ និងប្រជាជនមូលដ្ឋាន | • រៀបចំឱ្យមានសិក្ខាសាលាអប់រំណែនាំឱ្យបានទៀងទាត់ដើម្បីកាត់បន្ថយជម្លោះរវាងកម្មករសាងសង់ និងប្រជាពលរដ្ឋមូលដ្ឋាន<br>• បង្កើតនិងអនុវត្តច្បាប់ កាត់បន្ថយជំលោះឱ្យបានត្រឹមត្រូវ |
| លើកកម្ពស់សុវត្ថិភាពផ្លូវថ្នល់ | • ការបំពាក់នូវស្លាកសញ្ញាសុវត្ថិភាព និងសម្ភារៈ ផ្សេងៗទៀតដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរណ៍<br>• បង្កើតឱ្យមានតំបន់ឈប់សម្រាកនៅតាមផ្លូវដើម្បីកាត់បន្ថយភាពនឿយហត់របស់អ្នកបើកបរ |

### ជ. ផែនការគ្រប់គ្រងបរិស្ថាន

ចំណុចខាងក្រោមត្រូវបានបញ្ជាក់យ៉ាងច្បាស់ និងបញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថានរួមមានៈ

- ស្ថាប័នទទួលខុសត្រូវ (អ្នកអនុវត្ត និងទីប្រឹក្សា) ក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ ។ សម្រាប់គម្រោងផ្លូវថ្នល់ ភាគពាក់ព័ន្ធខាងក្រោមត្រូវមានតួនាទីដូចតទៅៈ
  - ក្រុមហ៊ុនសាងសង់ (អ្នកអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ជាក់ស្តែងជាដើម)
  - ជំនាញការប្រឹក្សា(អ្នកផ្តល់ប្រឹក្សាយោបល់ដល់ក្រុមហ៊ុនសាងសង់ ក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់)
  - ក្រសួងសាធារណការ និងដឹកជញ្ជូនជាម្ចាស់គម្រោង
  - ក្រសួងបរិស្ថាន ជាអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងបរិស្ថាន
  - រដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅទីតាំងគម្រោង។
- ដំណាក់កាលគម្រោង(ដំណាក់កាលមុនប្រតិបត្តិការ ប្រតិបត្តិការ និងបិទបញ្ចប់គម្រោង)
- ការសង្ខេបពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងដោយផ្អែកលើការវិភាគលើហេតុប៉ះពាល់បរិស្ថាន
- ការសង្ខេបពីវិធានការកាត់បន្ថយផលប៉ះពាល់
- ការពិពរណនាពីវិធានការកាត់បន្ថយដែលបានលើកឡើង
- ការប៉ាន់ស្មានតម្លៃលើការអនុវត្តវិធានការនីមួយៗ
- កម្មវិធីបណ្តុះបណ្តាលទៅលើរាល់សកម្មភាពផែនការគ្រប់គ្រងបរិស្ថាន។

### ឈ.ការវិភាគផ្នែកសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

នៅជំពូកនេះ ត្រូវរៀបរាប់ឱ្យបានក្បោះក្បាយដោយផ្អែកលើទិន្នន័យ និងព័ត៌មានដែលមានស្រាប់ស្តីពីអត្ថប្រយោជន៍នៃការអនុវត្តគម្រោង និងថ្លៃដើមសរុបនៃហេតុប៉ះពាល់លើបរិស្ថាន ដែលមិនអាចចៀសបានដោយសារការអនុវត្តគម្រោង ។

**៣. សន្និដ្ឋាន និងអនុសាសន៍**

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវបានរួមបញ្ចូលដោយការពិពណ៌នាច្បាស់លាស់ ដែលថាគម្រោង អាចកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងតាមរយការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ និងការពង្រឹងហេតុប៉ះពាល់វិជ្ជមាននៅក្នុងតំបន់គម្រោង។

បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការពិនិត្យរបាយការណ៍ វ.ហ.ប មានបង្ហាញក្នុងឧបសម្ព័ន្ធ១។ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការពិនិត្យរបាយការណ៍EMP មានបង្ហាញក្នុងឧបសម្ព័ន្ធ២។

## ៤.៣ ដំណាក់កាលអង្កេតតាមដានបរិស្ថាន

### ៤.៣.១ សេចក្តីផ្តើមនៃការអង្កេតតាមដានបរិស្ថាន

ក្រោយពីទទួលបានការអនុម័តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការអង្កេតតាមដានបរិស្ថានគួរត្រូវបានអនុវត្ត ដើម្បីផ្ទៀងផ្ទាត់បញ្ហាបរិស្ថានដែលបានព្យាករណ៍នៅក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រសិទ្ធិភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន។ វិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងទៀតនឹងត្រូវរៀបចំឡើង ប្រសិនបើការអង្កេតតាមដានបង្ហាញថាវិធានការកាត់បន្ថយហេតុប៉ះពាល់មិនមានប្រសិទ្ធភាព។

ការអង្កេតតាមដានបរិស្ថាន ត្រូវអនុវត្តទៅតាមពេលវេលាជាក់លាក់ដែលបានកំណត់ ដើម្បីវាយតម្លៃស្ថានភាពបរិស្ថាននីមួយៗនៅក្នុងដំណាក់កាលគម្រោងនីមួយៗ។ ម្យ៉ាងទៀតការអង្កេតតាមដានបរិស្ថានត្រូវបានអនុវត្ត ដើម្បីបញ្ជាក់ពីគោលដៅនៃការអភិរក្សដែលបានកំណត់អាចថែរក្សាលក្ខខណ្ឌបរិស្ថាន ឬមិនអាចថែរក្សាបាន ។

គោលបំណងនៃការអង្កេតតាមដានបរិស្ថាន នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តនៅក្នុងអំឡុងពេលសាងសង់ ប្រតិបត្តិការ និងបិទបញ្ចប់គម្រោងដើម្បីផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់។

### ៤.៣.២ ចំណាត់ថ្នាក់នៃការអង្កេតតាមដានបរិស្ថាន

ការអង្កេតតាមដានបរិស្ថានអាចធ្វើចំណាត់ថ្នាក់ជាពីរដូចខាងក្រោម៖

**ក. ការអង្កេតតាមដានបរិស្ថាន**

ការអង្កេតតាមដានបរិស្ថាន គឺដើម្បីបញ្ជាក់ពីប្រសិទ្ធភាពនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដែលអនុម័តយល់ព្រមដោយក្រសួងបរិស្ថាន។

នៅប្រទេសកម្ពុជា ការគ្រប់គ្រងបរិស្ថានមានចែងក្នុងប្រកាសលេខ៣៧៦របស់ក្រសួងបរិស្ថាន ស្តីពី "គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ" ហើយផែនការគ្រប់គ្រងបរិស្ថានត្រូវបានរួមបញ្ចូលជាផ្នែកមួយសំខាន់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គោលបំណងបឋមនៃផែនការគ្រប់គ្រងបរិស្ថាន គឺដើម្បីបញ្ជាក់ពីការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង។

ដូច្នេះ ផែនការគ្រប់គ្រងបរិស្ថាន គឺជាគន្លឹះសម្រាប់ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ប្រកបដោយប្រសិទ្ធភាព។

### ខ. ការអង្កេតតាមដានបរិស្ថានប្រកបដោយប្រសិទ្ធភាព

ការអង្កេតតាមដានបរិស្ថានប្រកបដោយប្រសិទ្ធភាព គឺបញ្ជាក់ពីប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលស្នើឡើងនៅក្នុងរបាយការណ៍ វ.ហ.ប។ ការអង្កេតតាមដានបរិស្ថានប្រកបដោយប្រសិទ្ធភាព គឺត្រូវអនុវត្តទាំងនៅក្នុងដំណាក់កាលនៃការសាងសង់ និងក្រោយសាងសង់ (ប្រតិបត្តិការ)។

ហេតុប៉ះពាល់នៅក្នុងដំណាក់កាលសាងសង់ អាចមានកម្រិតធ្ងន់ធ្ងរជាង ហេតុប៉ះពាល់នៅក្នុងដំណាក់កាលប្រតិបត្តិ។ ប៉ុន្តែរយៈពេលនៃផលប៉ះពាល់ក្នុងដំណាក់កាលប្រតិបត្តិគម្រោងអាចមានរយៈពេលយូរជាងដំណាក់កាលសាងសង់។

កម្មវិធីអង្កេតតាមដានបរិស្ថាន គឺជាផ្នែកមួយនៃផែនការគ្រប់គ្រងបរិស្ថានដែលបានចែងនៅក្នុងប្រកាសលេខ៣៧៦ របស់ក្រសួងបរិស្ថាន ។

### គ. ផែនការអង្កេតតាមដានបរិស្ថាន

គោលបំណងចម្បងនៃផែនការអង្កេតតាមដានបរិស្ថាន គឺត្រូវបានប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់។

ផែនការអង្កេតតាមដានបរិស្ថានគួរបញ្ចូលនូវធាតុផ្សំដូចខាងក្រោម៖

- ស្ថាប័នទទួលខុសត្រូវ(ទាំងអ្នកអនុវត្ត និងទីប្រឹក្សា)ក្នុងការអនុវត្តសកម្មភាពអង្កេតតាមដាននីមួយៗ
- សកម្មភាពអង្កេតតាមដាន អំឡុងពេលសាងសង់ ប្រតិបត្តិ និងបិទបញ្ចប់គម្រោង
- ប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវអង្កេតតាមដាន

  ប៉ារ៉ាម៉ែត្រ និងធាតុបឋមដែលត្រូវអង្កេតតាមដានសម្រាប់គម្រោងផ្លូវថ្នល់រួមមាន៖

  - គុណភាពខ្យល់ (TSP, CO, NO2, SO2, Pb ។ល។)
  - ជលសាស្ត្រ
  - គុណភាពទឹក (pH, TSS, BOD, DO, Oil និង Grease ។ល។)
  - សំឡេង និងរំញ័រ
  - សំណល់ចេញពីកាសាងសង់
- ទីតាំងដែលត្រូវអង្កេតតាមដាន
- វិធីសាស្ត្រនៃការអង្កេតតាមដាន
- ចំនួនដងនៃការអង្កេតតាមដាន

ផែនការគ្រប់គ្រងបរិស្ថាន គឺជាប្រភពដែលអាចបញ្ជាក់បន្ថែមពីការវាយតម្លៃប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន។

បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យផែនការអង្កេតតាមដានបរិស្ថាន គឺមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ៣។

### ឃ. របាយការណ៍អង្កេតតាមដានបរិស្ថាន

បន្ទាប់ពីរៀបចំផែនការអង្កេតតាមដានបរិស្ថាន ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន និងដាក់ជូនក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធតាមកាលកំណត់។

របាយការណ៍អង្កេតតាមដានបរិស្ថាន គឺត្រូវវិភាគតាមកាលកំណត់ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់ជាមួយនឹងការយកសំណាក និងការវិភាគទិន្នន័យជាក់លាក់និងធៀបជាមួយស្តង់ដាជាតិ។

របាយការណ៍អង្កេតតាមដានបរិស្ថានគួររួមបញ្ចូលនូវធាតុផ្សំដូចខាងក្រោម៖

- ការពិពណ៌នាពីអ្នកអនុវត្តអង្កេតតាមដាន
- សកម្មភាពអង្កេតតាមដាន អំឡុងពេលសាងសង់ ប្រតិបត្តិ និងបិទបញ្ចប់គម្រោង
- វិធីសាស្ត្រអង្កេតតាមដានរួមបញ្ចូលនូវ ម៉ោង និង ថ្ងៃ និងលក្ខខណ្ឌនៃទីតាំងសម្រាប់ធាតុនីមួយៗដែលត្រូវអង្កេតតាមដាន
- ធាតុ និងប៉ារ៉ាម៉ែត្រសម្រាប់អង្កេតតាមដានដែលត្រូវយកមកវាស់វែង និងវិភាគ ។

ប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវអង្កេតតាមដានសម្រាប់គម្រោងផ្លូវថ្នល់រួមមាន៖

- o គុណភាពខ្យល់ (TSP, CO, NO2, SO2, Pb ។ល។)
- o ជលសាស្ត្រ
- o គុណភាពទឹក(pH, TSS, BOD, DO, Oil និង Grease ។ល។)
- o សំឡេង និងរំញ័រ
- o កាកសំណល់សាងសង់

- ទីតាំងដែលត្រូវយកសំណាកសម្រាប់ធាតុអង្កេតតាមដាននីមួយៗ
- វិធីសាស្ត្រក្នុងការអង្កេតតាមដាន
- ភាពញឹកញាប់នៃអង្កេតតាមដាន
- លទ្ធផលនៃការអង្កេតតាមដាននីមួយៗដោយធៀបទៅនឹងស្តង់ដាបរិស្ថានជាតិនៅកម្ពុជា។
- ការសន្និដ្ឋាន និងសំណូមពររួមបញ្ចូលនឹងអនុសាសន៍ពីវិធានការកាត់បន្ថយហេតុប៉ះពាល់។

ផែនការអង្កេតតាមដានបរិស្ថាន គឺជាប្រភពដែលអាចបញ្ជាក់ពីការវាយតម្លៃប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន។

បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យផែនការអង្កេតតាមដានបរិស្ថាន គឺត្រូវបានពិពណ៌នានៅក្នុងឧបសម្ព័ន្ធ៥។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យរបាយការណ៍ វ.ហ.ប លើគម្រោងផ្លូវថ្នល់

| មាតិកា | ទំព័រ | មាន | គ្មាន | ការវាយតម្លៃ (ល្អ មធ្យម ខ្សោយ) | មតិយោបល់ |
|---|---|---|---|---|---|
| **ខ្លឹមសារសង្ខេប** | | | | | |
| គោលបំណងគម្រោង | | | | | |
| សកម្មភាពគម្រោង | | | | | |
| ធនធានបរិស្ថានដែលមានស្រាប់ | | | | | |
| លទ្ធផលនៃការប្រជុំសាធារណៈ | | | | | |
| វិសាលភាពនៃហេតុប៉ះពាល់លើបរិស្ថាន សង្គម និង វិធានការកាត់បន្ថយ | | | | | |
| ផែនការគ្រប់គ្រងបរិស្ថាន | | | | | |
| សេចក្តីសន្និដ្ឋាន និងអនុសាសន៍ | | | | | |
| **១. សេចក្តីផ្តើម** | | | | | |
| ព័ត៌មានទូទៅនៃគម្រោង (ប្រវត្តិគម្រោង មូលហេតុនៃការអភិវឌ្ឍគម្រោង និងស្ថានភាពទូទៅនៅទីតាំងគម្រោងជាដើម) | | | | | |
| គោលបំណងនៃការសិក្សា វ.ហ.ប | | | | | |
| វិធីសាស្រ្តនៃប្រមូល និង ការវិភាគទិន្នន័យ | | | | | |
| វិសាលភាពនៃការវាយតម្លៃ | | | | | |
| **២. វិធីសាស្រ្តវាយតម្លៃ** | | | | | |
| ការពិពណ៌នាពីវិធីសាស្រ្តនៃការប្រមូលទិន្នន័យនីមួយៗ | | | | | |
| ការពិពណ៌នាពីវិធីសាស្រ្តនៃការវិភាគហេតុប៉ះពាល់នីមួយៗ | | | | | |
| ការពិពណ៌នាពីវិធីសាស្រ្តក្នុងការគិតគូរពីវិធានការកាត់បន្ថយហេតុប៉ះពាល់ | | | | | |
| **៣. ក្របខ័ណ្ឌច្បាប់** | | | | | |
| ច្បាប់ អនុក្រឹត្យ បទបញ្ញត្តិ និងគោលនយោបាយនានាដែលទាក់ទងនឹងគម្រោង | | | | | |
| ផែនការ និងគោលនយោបាយបរិស្ថានដែលទាក់ទងនឹងគម្រោង | | | | | |
| ស្តង់ដារ បទបញ្ញត្តិបរិស្ថាននានារបស់ប្រទេសកម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលទាក់ទងនឹងគម្រោង | | | | | |

| | | | | | |
|---|---|---|---|---|---|
| គោលការណ៍ណែនាំនានាទាក់ទងនឹង បរិស្ថាន របស់ដៃគូអភិវឌ្ឍន៍ | | | | | |
| **៤. ការពិពណ៌នាពីគម្រោង** | | | | | |
| សារតា និងបទពិសោធន៍របស់ម្ចាស់គម្រោង | | | | | |
| ទីតាំងគម្រោងរួមបញ្ចូល ប្រភេទនៃការសាងសង់ និងសម្ភារៈសំណង់ ប្រភព និងការដឹកជញ្ជូន សម្ភារសំណង់ ព័ត៌មានទាក់ទងនឹងម៉ាស៊ីន វិធានការសុវត្ថិភាព កម្លាំងពលកម្ម សមភាព យែនឌ័រ ការប្រើប្រាស់គ្រឿងបរិក្ខារ ដោយភ្ជាប់ផែនទីរដ្ឋបាល និងទីតាំងគម្រោង | | | | | |
| ទីតាំងស្នាក់នៅរបស់កម្មករ និងផ្លូវចូលការដ្ឋានសាងសង់(ប្រភេទសំណង់ ទំហំ និងទីតាំងជាដើម) | | | | | |
| ប្រភេទគម្រោង និងកាលវិភាគនៃសកម្មភាពគម្រោង | | | | | |
| ស្ថានភាពគម្រោងក្នុងពេលបច្ចុប្បន្ន (ទទឹងផ្លូវ អ័ក្សផ្លូវជាដើម) | | | | | |
| ប្លង់គម្រោង (កំណាត់ផ្លូវថ្នល់បណ្តោយ ទទឹង ការសាងសង់ផ្លូវវាងជាដើម) | | | | | |
| ជម្រើសនៃគម្រោង (ការវិភាគជម្រើសគម្រោងជាមួយជម្រើសសូន្យ) | | | | | |
| **៥. ពិពណ៌នាបរិស្ថានដែលមានស្រាប់នៅក្នុងគម្រោង** | | | | | |
| ទិន្នន័យគោលធនធានរូបសាស្ត្រ | | | | | |
| • ភូមិសាស្ត្រ | | | | | |
| • សណ្ឋានដី និងប្រភេទដី | | | | | |
| • សំណឹកដី និងដីល្បាប់ | | | | | |
| • រយៈកម្ពស់ | | | | | |
| • អាកាសធាតុ (ខ្យល់ របបទឹកភ្លៀង សីតុណ្ហភាព និងរំហួតជាដើម) | | | | | |
| • គុណភាពខ្យល់ (ប្រចាំឆ្នាំ និងរដូវ) | | | | | |
| • សំឡេង និងរំញ័រ | | | | | |
| • ជលសាស្ត្រ | | | | | |
| • គុណភាពទឹកលើដី និងក្រោមដី | | | | | |
| • ការស្រុតដីចុះ | | | | | |
| ទិន្នន័យគោលធនធានជីវសាស្ត្រ | | | | | |
| • តំបន់ការពារធម្មជាតិ | | | | | |
| • សត្វព្រៃ | | | | | |
| • ព្រៃឈើ | | | | | |
| • ប្រភេទសត្វត្រូវអភិរក្ស | | | | | |

| | | | | | |
|---|---|---|---|---|---|
| ទិន្នន័យគោលធនធានសេដ្ឋកិច្ចសង្គម | | | | | |
| • សកម្មភាពសេដ្ឋកិច្ចចម្បងៗ | | | | | |
| • ប្រជាជន | | | | | |
| • ជនជាតិដើមភាគតិច ឬក្រុមជនជាតិភាគតិច | | | | | |
| • មុខរបរ | | | | | |
| • អប់រំ | | | | | |
| • សុខភាពសាធារណៈ | | | | | |
| • ស្ថានភាពឧក្រិដ្ឋកម្ម | | | | | |
| • បណ្តាញគមនាគមន៍ | | | | | |
| • សំណល់ (ប្រព័ន្ធប្រមូល បរិមាណ និងបោះចោល) | | | | | |
| • ទីតាំងបេតិកភណ្ឌវប្បធម៌ ឬប្រវត្តិសាស្ត្រ | | | | | |
| **៦. ការចូលរួមពីសាធារណជន** | | | | | |
| ការផ្សព្វផ្សាយសកម្មភាពគម្រោងដោយម្ចាស់គម្រោងទៅអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងតំបន់គម្រោងអភិវឌ្ឍន៍ | | | | | |
| លទ្ធផលនៃកិច្ចពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ (សំណួរ និងចម្លើយកត់ត្រាទុក) ម្ចាស់គម្រោង ក្រសួង ស្ថាប័ន អង្គភាព នាយកដ្ឋាន អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមូលដ្ឋាន | | | | | |
| មតិយោបល់ពីអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ | | | | | |
| ការពិភាក្សាជាមួយសហគមន៍មូលដ្ឋានដែលទទួលរងប៉ះពាល់ពីគម្រោង | | | | | |
| សេចក្តីសន្និដ្ឋានលើលទ្ធផលនៃការប្រជុំជាសាធារណៈ | | | | | |
| **៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ** | | | | | |
| ពិពណ៌នាពីហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមសេដ្ឋកិច្ច ក្នុងដំណាក់កាល មុនប្រតិបត្តិការ ប្រតិបត្តិការ និងបញ្ចប់គម្រោង (ហេតុប៉ះពាល់គឺអាស្រ័យលើប្រភេទគម្រោង។ ខាងក្រោមនេះគឺជាឧទាហរណ៍ហេតុប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីគម្រោងសាងសង់ផ្លូវថ្នល់។) | | | | | |
| ហេតុប៉ះពាល់លើធនធានរូបសាស្ត្រ | | | | | |
| • អាកាសធាតុ (របបទឹកភ្លៀង សីតុណ្ហភាព រំហួតជាដើម) | | | | | |
| • ភូមិសាស្ត្រ (ប្រភេទថ្ម រចនា គីមីភូមិសាស្ត្រ ជាដើម) | | | | | |
| • ដី (ការបំពុល និងសំណឹក) | | | | | |
| • រយៈកម្ពស់ (ជម្រាល) | | | | | |
| • ជលសាស្ត្រ (បរិមាណទឹក ល្បឿនលំហូរ) | | | | | |
| • គុណភាពទឹកលើដី (ទន្លេ បឹងជាដើម) | | | | | |

| | | | | | |
|---|---|---|---|---|---|
| • ទឹកក្រោមដី (កម្ពស់ទឹក និងគុណភាពទឹក) | | | | | |
| • គុណភាពខ្យល់ (ប្រភពច្បាស់លាស់ និងប្រភពមិនច្បាស់លាស់ និងតាម រដូវកាល) | | | | | |
| ហេតុប៉ះពាល់លើធនធានជីវសាស្ត្រ | | | | | |
| • អេកូឡូស៊ីក្នុងទឹក (ប្រភេទសត្វ និងរុក្ខជាតិ និងប្រភេទកម្រ) | | | | | |
| • តំបន់ការពារ | | | | | |
| • ជីវៈចម្រុះ | | | | | |
| ហេតុប៉ះពាល់លើសេដ្ឋកិច្ចសង្គម | | | | | |
| • រចនាសម្ព័ន្ធសង្គមនៃសហគមន៍ មូលដ្ឋាន | | | | | |
| • ការផ្លាស់ទីលំនៅដោយសារគម្រោង | | | | | |
| • ការផ្លាស់ប្តូរការប្រើប្រាស់ដី | | | | | |
| • ប្រជាសាស្ត្រដោយរួមបញ្ចូល យែនឌ័រ ស្ថានភាពសង្គម ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្រុមងាយរងគ្រោះ | | | | | |
| • ការអប់រំ និងជំនាញ (សាលារៀន កម្រិតអប់រំ និងជំនាញដែលមានស្រាប់ជាដើម) | | | | | |
| • ការងារ (ផ្លូវការ និងមិនផ្លូវការ អចិន្ត្រៃយ៍ និងតាមរដូវកាល) | | | | | |
| • បរិក្ខា និង សេវាកម្មក្នុងសហគមន៍ (សាលារៀន មណ្ឌលសុខភាព សេវាកម្ម សង្គ្រោះបន្ទាន់ បណ្ណាល័យ សេវាកម្មប្រមូលសំរាម ជាដើម) | | | | | |
| • សោភ័ណភាព (ទិដ្ឋភាព សំឡេង ក្លិន និងគុណភាពជីវិតជាដើម) | | | | | |
| • សុខភាពសាធារណ: (ជំងឺឆ្លង និងជំងឺមិនឆ្លង សុវត្ថិភាពសហគមន៍ជាដើម) | | | | | |
| • ឧក្រិត្យកម្ម និងសុវត្ថិភាពសហគមន៍ | | | | | |
| • តំបន់សែនព្រេន និងសាសនា | | | | | |
| • ទីតាំងវប្បធម៌ឬសាសនាសំខាន់ៗ | | | | | |
| • ទីតាំងប្រវត្តិសាស្តសំខាន់ៗ | | | | | |
| • បណ្តុំហេតុប៉ះពាល់ (ប្រសិនបើមាន) | | | | | |
| ពិពណ៌នាហេតុប៉ះពាល់លើបរិស្ថាន និងសង្គមជាវិជ្ជមាន (ហេតុប៉ះពាល់គឺអាស្រ័យលើប្រភេទគម្រោង។ ខាងក្រោមនេះគឺជាឧទាហរណ៍ហេតុប៉ះពាល់វិជ្ជមានដែលបណ្តាល មកពីគម្រោងសាងសង់ផ្លូវថ្នល់។) | | | | | |
| • ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ | | | | | |
| • ការធ្វើឱ្យប្រសើរឡើងបណ្តាញ ចរាចរណ៍ | | | | | |
| • ការធ្វើឱ្យប្រសើរឡើងបរិក្ខារសង្គម | | | | | |
| • ការធ្វើឱ្យប្រសើរឡើងសេវាកម្មសង្គម | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៨. ផែនការគ្រប់គ្រងបរិស្ថាន** | | | | | |
| សេចក្តីសង្ខេបពីហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយហេតុប៉ះពាល់ | | | | | |
| វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើង | | | | | |
| កម្មវិធីអង្កេតតាមដានបរិស្ថាន(ផែនការ) សម្រាប់អំឡុងពេលនៃការសាងសង់ ប្រតិបត្តិការ និងការបិទបញ្ចប់គម្រោងមានដូចខាងក្រោម<br>• ភ្នាក់ងារទទួលខុសត្រូវលើការអង្កេតតាមដានគម្រោង<br>• ប៉ារ៉ាម៉ែត្រសម្រាប់អង្កេតតាមដានត្រូវបានកំណត់<br>• វិធីសាស្ត្រក្នុងការអង្កេតតាមដាន<br>• គោលការណ៍ណែនាំ និងស្តង់ដារ បរិស្ថានសម្រាប់ការអង្កេតតាមដាន<br>• កាលវិភាគ និងវដ្តក្នុងការត្រួតពិនិត្យ<br>• ការវាយតម្លៃលទ្ធផលនៃការអង្កេតតាមដាន<br>• របាយការណ៍ប្រចាំត្រីមាស (របាយការណ៍អង្កេតតាមដាន បរិស្ថាន)ដែលត្រូវផ្ញើជូនក្រសួងបរិស្ថាន និងក្រសួង/ ស្ថាប័នពាក់ព័ន្ធ | | | | | |
| **៩. ការវិភាគសេដ្ឋកិច្ចនិង តម្លៃបរិស្ថាន** | | | | | |
| ការពិពណ៌នាពីថ្លៃដើមសរុបដោយរាប់បញ្ចូលតម្លៃនៃការខូចខាតបរិស្ថាន | | | | | |
| ការពិពណ៌នាពីការវិភាគថ្លៃដើម និងផលប្រយោជន៍ | | | | | |
| **១០. សន្និដ្ឋាន និងអនុសាសន៍** | | | | | |
| ការពិពណ៌នាពីសន្និដ្ឋាន និងអនុសាសន៍ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់ និងវិធានការកាត់បន្ថយហេតុប៉ះពាល់ | | | | | |

| សំណួរគន្លឹះ: | ទំព័រ | មាន | គ្មាន | មតិយោបល់ |
|---|---|---|---|---|
| ១. តើហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានត្រូវបាន ឬមិនត្រូវបានរៀបរាប់ច្បាស់លាស់នៅក្នុងរបាយការណ៍ វ.ហ.ប ? | | | | |
| ២. តើមានហេតុប៉ះពាល់ដែលមិនអាចចៀសផុតអ្វីខ្លះ?តើហេតុប៉ះពាល់ទាំងនោះអាចទទួលយកបានឬមិនបាន? | | | | |
| ៣. តើមានឬមិនមានការកំណត់ហេតុប៉ះពាល់នានាទៅលើតំបន់ការពារឬតំបន់បេតិកភណ្ឌវប្បធម៌? | | | | |
| ៤. តើ scoping matrix គ្របដណ្តប់ឬមិនគ្របដណ្តប់ហេតុប៉ះពាល់ទៅលើបរិស្ថាន និងសង្គម (ដោយបញ្ជាក់ពីកម្រិតប៉ះពាល់ដូចជាតិចតួច មធ្យម និងខ្លាំង)? | | | | |

## ឧបសម្ព័ន្ធ ២ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យផែនការគ្រប់គ្រងបរិស្ថានលើគម្រោងផ្លូវថ្នល់

| មាតិកា | ទំព័រ | មាន | គ្មាន | ការវាយតម្លៃ (ល្អ មធ្យម ខ្សោយ) | មតិយោបល់ |
|---|---|---|---|---|---|
| **១. ស្ថាប័នទទួលខុសត្រូវ** | | | | | |
| អ្នកអនុវត្តសកម្មភាពនីមួយៗនៃEMP | | | | | |
| ទីប្រឹក្សា ត្រួតពិនិត្យលើសកម្មភាពនីមួយៗ នៃEMP | | | | | |
| **២. ដំណាក់កាលគម្រោង (មុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គម្រោង)** | | | | | |
| ដំណាក់កាលមុនប្រតិបត្តិគម្រោង (ការរៀបចំផែនការគម្រោង) | | | | | |
| ដំណាក់កាលមុនប្រតិបត្តិគម្រោង (ការសាងសង់គម្រោង) | | | | | |
| ដំណាក់កាលប្រតិបត្តិគម្រោង | | | | | |
| ដំណាក់កាលបញ្ចប់គម្រោង | | | | | |
| **៣. ហេតុប៉ះពាល់អាចកើតឡើងជាអវិជ្ជមានលើបរិស្ថាន និងសេដ្ឋកិច្ចសង្គម (ហេតុប៉ះពាល់គឺអាស្រ័យលើប្រភេទ គម្រោង។ ខាងក្រោមនេះគឺជាឧទាហរណ៍ហេតុប៉ះពាល់ដែលអាចកើតឡើងជាអវិជ្ជមានលើ បរិស្ថាន និងសេដ្ឋកិច្ចសង្គម បណ្តាលមកពីគម្រោងសាងសង់ផ្លូវថ្នល់។)** | | | | | |
| ការបំពុលខ្យល់(ធូលី ឬឧស្ម័នដែលភាយចេញពីគ្រឿងចក្រ ឬយានយន្តជាដើម) | | | | | |
| ការបំពុលទឹកលើដី (ការកំពប់ហៀរប្រេង ឬសំណល់ចូលទន្លេ ការបញ្ចេញសំណល់រាវដោយមិនបានធ្វើប្រព្រឹត្តិកម្មជាដើម) | | | | | |
| បញ្ហាសំឡេង និងរំញ័រ (សំឡេង ឬ រំញ័រមកពីគ្រឿងចក្រសាងសង់ជាដើម) | | | | | |
| បញ្ហាកាកសំណល់ពីការសាងសង់ (សំណល់ពីការដ្ឋានសាងសង់ដូចជា សំណល់គ្រោះថ្នាក់ជាដើម) | | | | | |
| ជលសាស្ត្រ (ផ្លាស់ប្តូរលំហូរទឹក ឧទាហរណ៍ ការសាងសង់ផ្លូវអាចបណ្តាលឱ្យលំហូរទឹកនាពេលបច្ចុប្បន្នមានការផ្លាស់ប្តូរ) | | | | | |
| ការបាក់ស្រុតដី (ជញ្ជាំងទំនប់អាចស្រុតចុះ) | | | | | |
| តំបន់ទីជម្រកនៃប្រភេទសត្វងាយរងគ្រោះ (ការសាងសង់ផ្លូវអាចធ្វើឱ្យថយចុះទីជម្រក) | | | | | |
| សំណឹកដី (ការការពារតំបន់ជម្រាលមិនបានជិតដល់អាចបណ្តាលឱ្យមានសំណឹកដី) | | | | | |
| ការបាត់បង់ប្រភពចំណូលចម្បងៗ (ការបាត់បង់ប្រភពចំណូលចម្បងៗ ដោយសារការទិញលក់ដី) | | | | | |

| | | | | | |
|---|---|---|---|---|---|
| គ្រោះថ្នាក់ចរាចរណ៍(ការកើនឡើងចរាចរណ៍អាចធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍) | | | | | |
| ការថយចុះបរិស្ថានការងារ (វិធាន សុវត្ថិភាពការងារមិនគ្រប់គ្រាន់អាចបណ្តាលឱ្យមានគ្រោះថ្នាក់ក្នុងពេលសាងសង់) | | | | | |
| ការកើនឡើង ជម្លោះ ឬអំពើហឹង្សានៅមូលដ្ឋាន (ជម្លោះ ឬអំពើហឹង្សាមូលដ្ឋានអាចបណ្តាលមកពីលំហូរចូលនៃកម្មករសាងសង់ផ្លូវ) | | | | | |
| **៤. វិធានការកាត់បន្ថយហេតុប៉ះពាល់សម្រាប់សកម្មភាពគម្រោងនីមួយៗដែលស្នើឡើង(វិធានការនេះអាស្រ័យលើសកម្មភាពគម្រោង។ ខាងក្រោម ជាឧទាហរណ៍មួយចំនួនស្តីពីវិធានការណ៍កាត់បន្ថយសម្រាប់គម្រោងផ្លូវថ្នល់)** | | | | | |
| រៀបចំផែនការថែទាំគ្រឿងចក្រសាងសង់ឱ្យបានល្អ | | | | | |
| គ្រប់គ្រងការលេចជ្រាប ឬកំពប់ហៀរប្រេងឱ្យបានតឹងរឹង | | | | | |
| ការគ្រប់គ្រងសំណល់រាវតាមរយៈវិធានការបែប structure និងnon-structure | | | | | |
| ការគ្រប់គ្រងពេលវេលាសាងសង់ដើម្បីកាត់បន្ថយសម្លេងរំខាន ឬ រំញ័រ ដែលចេញពីគ្រឿងចក្រ | | | | | |
| រៀបចំប្រមូល និងការគ្រប់គ្រងសំរាមឱ្យបានសមស្រប | | | | | |
| រៀបចំដាក់លូ ឬសង់ស្ពានការពារការផ្លាស់ប្តូរលំហូរទឹក | | | | | |
| សាងសង់ជញ្ជាំងទំនប់ឱ្យត្រឹមត្រូវដើម្បីការពារមិនឱ្យមានការស្រុតដី | | | | | |
| រៀបចំដាក់លូដើម្បីការពារការថយចុះទីជម្រក | | | | | |
| រៀបចំជម្រាលឱ្យបានត្រឹមត្រូវ ដើម្បីការពារសំណឹកដី | | | | | |
| រៀបចំវិធានការទ្រទ្រង់ជីវភាពសម្រាប់ ប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយ សារគម្រោង | | | | | |
| រៀបចំសិក្ខាសាលាស្តីពីសុវត្ថិភាពសម្រាប់កម្មករ | | | | | |
| រៀបចំវិធានការសុវត្ថិភាពចរាចរណ៍ (រឹតបណ្តឹងល្បឿនបើកបរជាដើម) | | | | | |
| **៥ ការប៉ាន់ស្មានតម្លៃ និងកាលវិភាគសម្រាប់ការអនុវត្តវិធានការកាត់បន្ថយនីមួយៗ** | | | | | |
| ការកំណត់ពីការប៉ាន់ស្មានតម្លៃលើវិធានការនីមួយៗឱ្យបានច្បាស់លាស់ | | | | | |
| កាលវិភាគសម្រាប់ការអនុវត្តវិធានការកាត់បន្ថយនីមួយៗ | | | | | |

| សំណួរគន្លឹះ | ទំព័រ | មាន | គ្មាន | មតិយោបល់ |
|---|---|---|---|---|
| ១. រៀបរាប់ពីភ្នាក់ងារ និងស្ថាប័នទទួលខុសត្រូវ (រួមទាំងក្រុមហ៊ុនសាងសង់) និងភារកិច្ចរបស់ស្ថាប័នទាំងនោះ | | | | |
| ២. វិធានការកាត់បន្ថយនិងទ្រទ្រង់ត្រូវមានលក្ខណៈបែបបច្ចេកទេស និងវិទ្យាសាស្ត្រត្រឹមត្រូវ | | | | |
| ៣. ហេតុប៉ះពាល់ធ្ងន់ធ្ងរដែលមិនអាចបញ្ចៀសឬកាត់បន្ថយបានត្រូវរៀបរាប់ឱ្យបានក្បោះក្បាយ | | | | |
| ៤. វិធានការគាំទ្រដើម្បីពង្រឹងហេតុប៉ះពាល់វិជ្ជមាន ត្រូវបានអភិវឌ្ឍឡើងយ៉ាងសមស្រប | | | | |
| ៥. បទពិសោធន៍ពីគម្រោងមុនដែលមានលក្ខណៈស្រដៀងគ្នាត្រូវបញ្ចូលទៅក្នុងវិធានការកាត់បន្ថយ | | | | |
| ៦. តើការប៉ាន់ស្មានតម្លៃទៅលើវិធានការកាត់បន្ថយហេតុប៉ះពាល់មានភាពសមហេតុផល និងជាក់ស្តែងឬមិនមាន? | | | | |
| ៧. តើកម្មវិធីបណ្តុះបណ្តាលសម្រាប់ការអនុវត្តEMPត្រូវបានរៀបរាប់ឬមិនរៀបរាប់ច្បាស់លាស់? | | | | |

## ឧបសម្ព័ន្ធ ៣ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យផែនការអង្កេតតាមដានបរិស្ថានលើគម្រោងផ្លូវថ្នល់

| មាតិកា | ទំព័រ | មាន | គ្មាន | ការវាយតម្លៃ (ល្អ មធ្យម ខ្សោយ) | មតិយោបល់ |
|---|---|---|---|---|---|
| **១. ស្ថាប័នទទួលខុសត្រូវ** | | | | | |
| អ្នកទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពអង្កេតតាមដាននីមួយៗ | | | | | |
| ទីប្រឹក្សាទទួលខុសត្រូវក្នុងការពិនិត្យការអនុវត្តសកម្មភាពអង្កេតតាមដាននីមួយៗ | | | | | |
| **២. ដំណាក់កាលគម្រោង (មុនប្រតិបត្តិ ប្រតិបត្តិ និង បញ្ចប់គម្រោង)** | | | | | |
| ដំណាក់កាលមុនប្រតិបត្តិគម្រោង (ការរៀបចំផែនការ) | | | | | |
| ដំណាក់កាលមុនប្រតិបត្តិគម្រោង (ការសាងសង់) | | | | | |
| ដំណាក់កាលប្រតិបត្តិគម្រោង | | | | | |
| ដំណាក់កាលបិទបញ្ចប់គម្រោង | | | | | |
| **៣. ប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវអង្កេតតាមដាន (ប៉ារ៉ាម៉ែត្រ និងធាតុអាចមានការប្រែប្រួលអាស្រ័យលើសកម្មភាពគម្រោង។ ខាងក្រោមនេះជាឧទាហរណ៍នៃប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវអង្កេតតាមដានសម្រាប់គម្រោងផ្លូវថ្នល់។)** | | | | | |
| គុណភាពខ្យល់(TSP, CO, NO2, SO2, Pb ។ល។) | | | | | |
| គុណភាពទឹកលើដី(pH, turbidity, Oil និង Grease, DO. ។ល។) | | | | | |
| សម្លេង និងរំញ័រ | | | | | |
| កាកសំណល់ពីការសាងសង់ (បរិមាណសំណល់ នីតិវិធី និងប្រព័ន្ធចាក់ចោលសំណល់) | | | | | |
| ជលសាស្ត្រ (បរិមាណទឹក និងល្បឿនទឹកហូរ) | | | | | |
| ការបាក់ស្រុតដី (រយៈកម្ពស់សណ្ឋានដីនាពេលបច្ចុប្បន្ន) | | | | | |
| ប្រព័ន្ធអេកូឡូស៊ី (ស្ថានភាពទីជម្រកនៃប្រភេទសត្វសំខាន់ៗ) | | | | | |
| ដី (ការបំពុល និងស្ថានភាពសំណឹក) | | | | | |
| គ្រោះថ្នាក់ចរាចរណ៍ (បរិមាណនៃគ្រោះថ្នាក់ចរាចរណ៍) | | | | | |
| បរិស្ថានកន្លែងធ្វើការ (បរិមាណនៃគ្រោះថ្នាក់ពីការសាងសង់) | | | | | |
| សុខភាពសាធារណៈ (អត្រាជំងឺឆ្លងជាដើម) | | | | | |
| **៤. ទីតាំងដែលត្រូវអង្កេតតាមដាន** | | | | | |
| ការកំណត់ទីតាំងសម្រាប់ចំណុចដែលត្រូវអង្កេតតាមដាននីមួយៗឱ្យបានច្បាស់លាស់ | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៥. វិធីសាស្ត្រក្នុងការអង្កេតតាមដាន** | | | | | |
| ការកំណត់ពីវិធីសាស្ត្រក្នុងការអង្កេតតាមដានឱ្យបានច្បាស់លាស់ | | | | | |
| **៦. ភាពញឹកញាប់នៃការអង្កេតតាមដាន** | | | | | |
| ការកំណត់ភាពញឹកញាប់នៃការអង្កេតតាមដានក្នុងការយកសំណាកនីមួយៗឱ្យបានច្បាស់លាស់ | | | | | |
| **៧. ការរៀបចំរបាយការណ៍** | | | | | |
| ការកំណត់ពីភាពញឹកញាប់ (កាលវិភាគ) ក្នុងការដាក់បញ្ជូនរបាយការណ៍ អង្កេតតាមដានបរិស្ថាន (EMoP) | | | | | |
| ការកំណត់ពីស្ថាប័នដែលត្រូវដាក់បញ្ជូនរបាយការណ៍ | | | | | |

| **សំណួរគន្លឹះ** | **ទំព័រ** | **មាន** | **គ្មាន** | **មតិយោបល់** |
|---|---|---|---|---|
| ១. តើទីតាំង និងភាពញឹកញាប់នៃការយកសំណាកនៅក្នុងទីតាំងគម្រោងមានភាពប្រាកដប្រជាឬមិនមានភាពប្រាកដប្រជា តាមបែបបច្ចេកទេស និងថវិកាសមរម្យ? | | | | |
| ២. តើវិធីសាស្ត្រយកសំណាកនៅក្នុងទីតាំងគម្រោងមាន ភាពប្រាកដប្រជាឬមិនមានភាពប្រាកដប្រជា តាមបែបបច្ចេកទេស និងថវិកាសមរម្យ? | | | | |
| ៣. តើមានការកំណត់ឬមិនមានការកំណត់បានច្បាស់លាស់ពីប្រភពថវិកាសម្រាប់សកម្មភាព អង្កេតតាមដាននីមួយៗ? | | | | |

## ឧបសម្ព័ន្ធ ៩ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ពិនិត្យរបាយការណ៍អង្កេតតាមដានបរិស្ថានលើគម្រោងផ្លូវថ្នល់

| មាតិកា | ទំព័រ | មាន | គ្មាន | ការវាយតម្លៃ (ល្អ មធ្យម ខ្សោយ) | មតិយោបល់ |
|---|---|---|---|---|---|
| **១. ស្ថាប័នទទួលខុសត្រូវ** | | | | | |
| អ្នករៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន ដោយរួមបញ្ចូលទាំងការយកសំណាក និងវិភាគទិន្នន័យ | | | | | |
| ទីប្រឹក្សាទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន ដោយរួមបញ្ចូលការពិនិត្យគុណភាពនៃទិន្នន័យដែលត្រូវវិភាគ | | | | | |
| **២. វិធីសាស្ត្រក្នុងការអង្កេតតាមដាន ដោយរួមបញ្ចូល ពេលវេលា និងលក្ខណៈទីតាំងនៃធាតុដែលត្រូវអង្កេតតាមដាននីមួយៗ** | | | | | |
| ការកំណត់ពីវិធីសាស្ត្រសម្រាប់ធាតុដែលត្រូវអង្កេតតាមដាននីមួយៗឱ្យបានច្បាស់លាស់ | | | | | |
| ពេលវេលាក្នុងការអង្កេតតាមដាន និងលក្ខណៈទីតាំងសម្រាប់ធាតុអង្កេតតាមដាននីមួយៗ | | | | | |
| **៣. ប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវវាស់វែង និងវិភាគ (ប៉ារ៉ាម៉ែត្រ និងធាតុមានការប្រែប្រួលអាស្រ័យលើសកម្មភាព គម្រោង។ ខាងក្រោមនេះជាឧទាហរណ៍នៃប៉ារ៉ាម៉ែត្រ និងធាតុដែលត្រូវអង្កេតតាមដានសម្រាប់គម្រោងផ្លូវថ្នល់។)** | | | | | |
| គុណភាពខ្យល់ (TSP, CO, NO2, SO2, Pb។ល។) | | | | | |
| គុណភាពទឹកលើដី (pH, TSS, BOD, Oil និង Grease, DO. ។ល។) | | | | | |
| សម្លេង និងរំញ័រ | | | | | |
| កាកសំណល់ពីការសាងសង់ (បរិមាណសំណល់ នីតិវិធី និងប្រព័ន្ធចាក់ចោលសំណល់) | | | | | |
| ជលសាស្ត្រ(បរិមាណទឹក និងល្បឿនទឹកហូរ) | | | | | |
| ការបាក់ស្រុតដី | | | | | |
| ប្រព័ន្ធអេកូឡូស៊ី (ស្ថានភាពទីជម្រកនៃប្រភេទសត្វសំខាន់ៗ) | | | | | |
| ដី (ការបំពុល និងស្ថានភាពសំណឹក) | | | | | |
| គ្រោះថ្នាក់ចរាចរណ៍ (ចំនួនករណីនៃគ្រោះថ្នាក់ចរាចរណ៍) | | | | | |
| បរិស្ថានកន្លែងធ្វើការ(ចំនួនករណីនៃគ្រោះថ្នាក់ពីការសាងសង់) | | | | | |
| សុខភាពសាធារណៈ(អត្រាជំងឺឆ្លងជាដើម) | | | | | |
| **៤. ទីតាំងដែលត្រូវអង្កេតតាមដាន** | | | | | |
| ការកំណត់ទីតាំងសម្រាប់ចំណុចដែលត្រូវអង្កេតតាមដាននីមួយៗឱ្យបានច្បាស់លាស់ | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៥. វិធីសាស្ត្រក្នុងការអង្កេតតាមដាន** | | | | | |
| ការកំណត់ពីវិធីសាស្ត្រក្នុងការអង្កេតតាមដានឱ្យបានច្បាស់លាស់ | | | | | |
| **៦. ភាពញឹកញាប់នៃការអង្កេតតាមដាន** | | | | | |
| ការកំណត់ភាពញឹកញាប់នៃការអង្កេតតាមដានក្នុងការយកសំណាកនីមួយៗឱ្យបានច្បាស់លាស់ | | | | | |
| **៧. លទ្ធផលនៃការអង្កេតតាមដានធាតុនីមួយៗ** | | | | | |
| ទិន្នន័យអង្កេតតាមដានធាតុនីមួយៗ | | | | | |
| លទ្ធផលនៃការប្រៀបធៀបទិន្នន័យអង្កេតតាមដានធាតុនីមួយៗជាមួយនឹងស្តង់ដាដែលបានកំណត់ | | | | | |
| **៨. សន្និដ្ឋាន និងការសំណូមពរ** | | | | | |
| ការពិពណ៌នាឱ្យបានច្បាស់លាស់ពីការប្រៀបធៀបលក្ខខណ្ឌបរិស្ថានជាមួយនឹង ស្តង់ដារច្បាប់ | | | | | |
| ការពិពណ៌នាឱ្យបានច្បាស់លាស់ពីការតាមដានវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលចាំបាច់ប្រសិនបើមាន | | | | | |

| **សំណួរគន្លឹះ** | **ទំព័រ** | **មាន** | **គ្មាន** | **មតិយោបល់** |
|---|---|---|---|---|
| ១. តើការត្រួតពិនិត្យគុណភាពនៃទិន្នន័យវិភាគអាចត្រូវបានធានាដោយរបៀបណា? | | | | |
| ២. តើវិធីសាស្ត្រវិភាគមានតម្លៃសមរម្យឬមិនសមរម្យ (cost-effective)? | | | | |

# បញ្ជីឈ្មោះសមាជិកក្រុមការងារ ទីប្រឹក្សា និងជំនាញការ EIA/EMP

## ពិនិត្យកែសម្រួល និងផ្តល់យោបល់ដោយ

| | |
|---|---|
| ឯកឧត្តម តូច ចាន់កុសល | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ឯកឧត្តម នូ វឌ្ឍនៈ | អគ្គនាយកបច្ចេកទេស ក្រសួងសាធារណការ និងដឹកជញ្ជូន |

## រៀបរៀងដោយ

| | |
|---|---|
| លោក ប្រុក ណូរីដា | ប្រធាននាយកដ្ឋាននៃនាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក អ៊ុយ សម្បត្តិ | អនុប្រធានការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក ស្រី វីរៈ | មន្ត្រីនៃការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក បូ ផៃយ៉ា | មន្ត្រីនៃការិយាល័យបរិស្ថាន និងសង្គមនៃនាយកដ្ឋានផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក ម៉ាញ វុត្ថា | អនុប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក ង៉ិល សុវណ្ណារិទ្ធ | មន្ត្រីការិយាល័យ សហប្រតិបត្តិការទ្វេភាគីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន |
| លោក សុង គីមហេង | មន្ត្រីការិយាល័យ រដ្ឋបាលនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន |

## ផ្តល់ប្រឹក្សាបច្ចេកទេសដោយ

| | |
|---|---|
| លោក ITO Tsuyoshi | ជំនាញការបរិស្ថាន និងសង្គម (EIA និងEMP) |
| លោក ពេញ សុជាតិ | ជំនួយការបច្ចេកទេស |

# ROAD

# ENVIRONMENTAL

# GUIDEBOOK

# Contents

**DEFINITION OF TERMS** ........ **i**
**CHAPTER I: INTRODUCTION** ........ **1**
1.1 BACKGROUND ........ 1
1.2 OBJECTIVE AND SCOPE OF THE REG ........ 1
1.3 GENERAL STEPS IN CONDUCTING THE EIA ........ 2
1.3.1 Screening ........ 2
1.3.2 Scoping ........ 2
1.3.3 Baseline Data Collection in the Project Area ........ 2
1.3.4 Impact Assessment ........ 2
1.3.5 Consideration of Mitigation Measures ........ 2
1.3.6 Consideration of Environmental Management Plan (EMP) ........ 2
1.4 PROJECT CYCLE AND THE EIA ........ 2
1.4.1 General Project Cycle and the EIA ........ 2
1.4.2 Road Project Cycle and the EIA Steps ........ 3
**CHAPTER 2: RELEVANT LAWS, SUB-DECREES AND PRAKAS** ........ **5**
**CHAPTER 3: EIA PROCESS STEPS INVOLVING THE MPWT IN CAMBODIA** ........ **10**
3.1 EIA PROCESS STEPS ACROSS THE NATION OF CAMBODIA ........ 10
3.1.1 IEIA/EIA Report Preparation Phase ........ 10
3.1.2 IEIA/EIA Report Review Phase ........ 10
3.1.3 Environmental Monitoring Phase ........ 11
3.2 EIA PROCESS PHASES INVOLVING THE MPWT IN CAMBODIA ........ 11
3.2.1 IEIA/EIA Report Preparation Phase ........ 12
3.2.2 EIA Report Review Phase ........ 12
3.2.3 Environmental Monitoring Phase ........ 12
**CHAPTER 4: PRACTICAL EIA PROCESS METHODS INVOLVING THE MPWT** ........ **14**
4.1 EIA REPORT PREPARATION PHASE ........ 14
4.1.1 EIA Report Contents ........ 14
4.2 EIA REPORT REVIEW PHASE ........ 16
4.2.1 Introduction to the EIA Report Review Phase ........ 16
4.2.2 Practical Methods for the EIA Report Review ........ 16
4.3 ENVIRONMENTAL MONITORING PHASE ........ 20
4.3.1 Introduction to Environmental Monitoring ........ 20
4.3.2 Categories of Environmental Monitoring ........ 21
**APPENDICES** ........ **23**
APPENDIX 1 CHECKLIST FOR REVIEWING AN EIA REPORT FOR A ROAD PROJECT ........ 23
APPENDIX 2 CHECKLIST FOR REVIEWING AN EMP FOR ROAD A PROJECT ........ 27
APPENDIX 3 CHECKLIST FOR REVIEWING AN EMOP FOR A ROAD PROJECT ........ 29
APPENDIX 4 CHECKLIST FOR REVIEWING AN EMOR FOR A ROAD PROJECT ........ 30

# DEFINITION OF TERMS

| | |
|---|---|
| Alternative Analysis | Alternative Analysis is the evaluation of the different choices available to achieve a particular project management objective. It is an analytical comparison of different factors, such as operational costs, risks, effectiveness, and potential shortfalls in operational capacity. |
| Cost Benefit Analysis | Cost Benefit Analysis is a systematic process for calculating and comparing the related benefits and costs of a decision, policy (with particular regard to government policy) or project (in general). |
| Cumulative Impacts | The combination of multiple impacts from existing projects, the proposed project, and anticipated future projects that may result in significant adverse and/or beneficial impacts that cannot be expected in the case of a stand-alone project. |
| Development Partners: | Foreign donors, which assist developing countries financially and technically, such as the World Bank, Asian Development Bank, Japan International Cooperation Agency (JICA), and Korea International Cooperation Agency (KOICA). |
| EIA | Environmental Impact Assessment (EIA) is the detailed assessment of the physical, biological and socio-economic environment, and the resources. It is based mainly on primary data from the area within or the area surrounding the project site. It forms the basis for the identification, prediction and analysis of potential adverse environmental and social impacts caused by the project activities, and aims to identify actions to minimize the negative impacts and maximize the positive impacts. |
| EMoP | Environmental Monitoring Plan (EMoP) is a project specific plan developed to validate the effectiveness of the implemented mitigation measures during the construction and/or operation of a project. |
| EMoR | Environmental Monitoring Report (EMoR) is a periodical report, including the monitoring data compared against each conservation target to validate the effectiveness of the implemented mitigation measures during the construction and/or operation of a project. |
